ពេល Royក៏ដូចជាចិត្រា ពួកគេរវេភ្នែកសម្លឹងគ្នាទៅវិញទៅមក លោកឱត សាម៉ុននិយាយពន្យល់បន្ថែមក្នុងសំឡេងខ្សឹបៗ៖

«ពូឱ្យឯកមាន! ប៉ូលិសមកពីផ្នែកhackនិងជើងកាងសាលាម្នាក់! ពីរនាក់នេះដើរតួជា អ្នកបើកឡាននិងអង្គរក្ស! ពូចង់បានប៉ូលិសតែងខ្លួនជាអង្គរក្សតាមពីក្រោយមួយឡានទៀត!»

ការបាត់ខ្លួននារីអភិជនបួននាក់មុនៗ នៅស្ងាត់សូន្យដល់ពេលនេះ ធ្វើឲ្យស្នងការក្មេងដែលមានសញ្ញាប័ត្របរទេស សឹងដើរងើបមុខមើលគេឯងមិនចង់កើត ទម្រាំបើពេលនេះ ម្ចាស់ពិធីកំពុងដេកត្រដរខ្យល់នៅក្នុងពេទ្យហើយកូនចៅកំពុងជ្រួលច្របល់ បែរជាខាងភ្ញៀវទទួលបានការកោះអញ្ជើញដូចធម្មតា?

«បាទទាន!»

Roy ឆ្លើយប្រញាប់ ធ្វើឱ្យលោកឱត សាម៉ុនបន្តបន្ថែមមករកអនាគតកូនប្រសា៖

«រឿងមួយទៀត ពូចង់ឱ្យលោកស្នងការបន្ថែមការតាមដាននាងRose២៤ ម៉ោងលើម្ភៃបួនម៉ោង!»

ស្នងការរវេភ្នែកគិត។ ដៃចុចបើកអាយកូមហើយនិយាយមួយៗ៖

«ឱ្យផ្នែកឯកសារតាមដានរកប្រវត្តិស្រីមេពីធីការរបស់មហាវីន Rose ឈ្មោះដើម វិធីតា!»

ឱត សាម៉ុនឃើញហើយ ងាកមកបញ្ជានាយសក្តិបួនយើងម្តង៖

«មានការងារផ្សេង! ឆាប់ចុះមក!»

វគ្គ បេសកកម្មឥតព្រាងទុក

នៅក្នុងសួនមន្ទីរពេទ្យ....

មេឃងងឹតស្លុបទៅហើយ....

«អាមាន! ឯងនៅឯណា? នៅក្បែរផ្ទះអ្នកនាងផានូអត់?»

ឯកមានឆ្លើយមកវិញតាមធម្មតា៖

«យើងនៅក្នុងផ្ទះគេ!»

«អ្វេះ?»

គេសួរមួយម៉ាត់ខ្លីទេនឹកឃើញឡើងវិញ ហើយថាជើងឆើត ឯកមាន មានបណ្ដាញរបស់ផានូ និងអមរាជាក្នុងដៃគេម្ភៃបួនម៉ោង ពួកនាងជួបអ្នកណា ធ្វើអ្វីក៏មិនអាចរំលងពីនាយ Hacker ដែរ។

ចិត្រាសួរបញ្ជាក់៖

«ហើយគេព្រមឲ្យឯងទៅជាមួយដែរ?»

ឯកមានឆ្លើយតបដោយបោះសម្ដីធ្វើខែងរ៉ែង៖

«បើគ្មានយើង គេម៉េចហ៊ានប្រថុយទៅ?»

ហៅនាងថា «គេ» ពេញៗមាត់ អ្នកណាក៏ដឹងថាឯកមានកំពុងមានអារម្មណ៍ល្អជាមួយនារីអភិជននេះដែរ។ ចិត្រាញញឹមហើយពោលឌឺដង៖

«ឧត្តមសេនីយ៍ថា បើឯងឲ្យរបូតនាងបាត់ ឯងនឹងត្រូវថ្មោងហើយអាមាន! ក្បាលឯងរបូតក៏ដោយ ត្រូវនាំនាងមកផ្ទះវិញ! ឮ?»

ឯកមាន បែរជាមិនខឹងមិនរអ៊ូ គេតបមកវិញហាក់រីករាយ៖

«អូខេ យើងព្រម! ព្រោះជាតិនេះ អាមានយើងស្រលាញ់តែស្រីមានៗស្អាតៗ!»

គេដាក់ទូរសព្ទចុះ ហើយបែរបកក្រោយ ចំពេលឃើញនាយRoy រត់ចេញទៅទាំងដៃកាន់អាយកូមពីរបី  ចំណែកឧត្តមសេនីយ៍ដើរតម្រង់មករកខ្លួនដោយជំហានវែងៗ។

«ចិត្រា!»

គាត់ហៅពីចម្ងាយ ហាក់ប្រញាប់ជាងជំហានជើងនោះទៅទៀត។

នាយសក្តិ៤រត់ចូលទៅ បុរសចំណាស់ចាប់ផ្ដើមខ្សឹបខ្សៀវដាក់នាយ៖

«ចិត្រា!»

«បាទទាន!»

«ខ្ញុំចេះតែមានអារម្មណ៍មិនល្អ!»

គេដកដង្ហើមយូរសម្លឹងមុខគាត់ មុនពេលឱនមុខគោរព។ សម្រាប់ឧត្តមសេនីយ៍មួយរូបក្នុងប្រតិបត្តិការដ៏សំខាន់  ការដែលគាត់ប្រើអារម្មណ៍មកនិយាយស្ដាប់ទៅអាចថាអស់សំណើចបាន។ ប៉ុន្តែករណីពេលនេះ គឺខុសប្លែក។ ខ្លួនគេជាតិចិត្រា គេក៏មានពិភាល់ដូចគ្នា ថាគ្រប់យ៉ាងដូចជាមិនមែនចុងបញ្ចប់ទេ តែវាហាក់បីដូចជាទើបនឹងចាប់ផ្ដើមតែប៉ុណ្ណោះ។

វាអាចជាការចាប់ផ្ដើមដែលគួរឲ្យថប់បារម្ភ តែមិនអាចរកគន្លឹះមកចាប់ចំណុចបកស្រាយបាន។

«កូនប្រពន្ធខ្ញុំដាក់ប៉ូលិសទៅថែមហើយ! អមរាជាខ្ញុំមិនឲ្យចេញទៅណាទាំងអស់យប់នេះ!»

«បាទទាន!»

គេឆ្លើយយ៉ាងរហ័ស ហើយកែវភ្នែកលេចឡើងនូវរង្វង់មុខដូចគំនូររបស់អ្នកនាងតូចគួរឲ្យស្រលាញ់។

«ចិត្រា!»

គាត់ហៅគេទៀតដើម្បីប្រមូលការរិះគិតរបស់គេត្រឡប់មកទីនេះវិញ។

«បាទទាន!»

គាត់គោះស្មានាយហើយនិយាយមួយៗ៖

«ទោះបីជា Royបញ្ជូនពួកប៉ូលិសទៅយាមកាមនៅផ្ទះ ប៉ុន្តែលោកឃើញហើយវរសេនីយ៍ត្រី! កម្រិតរបស់ចោរ មានប៉ុន្មានគីឡូដែលកំពុងដើរមុនយើង!!»

គេគិតភ្លែតដល់ឯកមាន ហើយងើបមុខមកសម្លឹងជនចំណាស់ដ៏មានបទពិសោធន៍នៅចំពោះមុខខ្លួន។ ការវាយតម្លៃរបស់គាត់គ្មានត្រង់ណាគួរឲ្យសង្ស័យថាស្មារតីបង្ក្រាបបទល្មើសរបស់គាត់ចុះថយទៅតាមវេលាកាលទេ។

គាត់ដកដង្ហើមធំនៅចំពោះមុខកែវភ្នែកមុតថ្លារបស់នាយ។ ដោយមិនរង់ចាំឲ្យគាត់និយាយបន្ថែម គេអះអាងភ្លាម៖

«អ្នកនាងអមរាដា ជាអាទិភាពរបស់ខ្ញុំ! ខ្ញុំនឹងរក្សាសុវត្ថិភាពគាត់!»

ប៉ូលិសទាំងក្រុម ហើយគាត់ក៏មិនទុកចិត្ត តើគាត់កំពុងគិតដល់រឿងអ្វីខ្លះបានជាបង្ខំឲ្យនាយត្រឡប់ទៅវិញហាក់បីដូចជាទុកចិត្តនាយជាង?

គេមិនមានពេលសួរបញ្ជាប់ចម្លល់ទេ មានតែអោនកាយហើយចាកចេញ...

នៅលើម៉ូតូដ៏ធំរបស់ខ្លួន គេចាប់ផ្ដើមពាក់កាសនិយាយជាមួយ ឯកមានៈ

«ឯងត្រូវទាក់ទងមកយើងកុំឲ្យបាត់ដានឲ្យសោះអាមាន! មហាវិនគ្មានរឿងអីថានៅពីក្រោយការកោះហៅជប់លៀងម៉ោង៩នេះទេ មនុស្សទើបនឹងរួចពីស្លាប់ហើយបន្ទប់នោះរុយមួយក៏ចូលមិនបានផងប៉ូលិសយាមម៉ត់ចត់មហាវិនមិនអាចទាក់ទងអ្នកណាបានទាំងអស់! ហើយម្នាក់ស្រីឈ្មោះ Rose មេពិធីការរបស់គេនោះក៏បដិសេធប្រាប់ស្នងការRoyមុននេះតាមឆាតថាគេមិនដឹងរឿងសមោសរពណ៌ព្រះចន្ទម៉ោង៩នេះដូចគ្នា! អ្វីៗកាន់តែជ្រៅហើយ!»

«សាហាវម៉េះ?»

ឯកមានសួរបកមកវិញហាក់ភ័យព្រួយចំពោះព័ត៌មានចុងក្រោយនេះ។ នាយគ្រាន់តែជាអ្នកលេងបណ្ដាញប៉ុណ្ណោះ មានអាវុធនិងក្បាច់គុណឯណាអាចទប់ទល់បាន ប្រសិនពិតជាមានហេតុការណ៍អរកុសលណាមួយកើតឡើង?

«អ្ហែងម៉េចមិនឃាត់ផានូ អាត្រា? ពិធីអីម្ចាស់កម្មវិធីមិនដឹងផង តើអាណាវិញអ្នកអញ្ជើញនាងហើយវាចង់យកនាងទៅណា?»

ឮសំណួរឯកមាន ចិត្រាពិភាល់នឹកភ្លាមទៅដល់អ្នកនាងតូចអមរាដាដែលនៅឯផ្ទះ។ មាត់គេឆ្លើយតបទាំងចិត្តខ្វល់ខ្វាយអនេកៈ

«ស្នងការ Roy បញ្ជូនប៉ូលិសទៅច្រើនហើយ! ឯងរកល្បិចពន្យារពេលទៅ! ចំណែកនុយពេលនេះត្រូវដាក់ព្រោះគ្មានឱកាសចាប់ត្រីទេ!»

ឯកមាននៅស្ងាត់ស្មៀមគ្មានចម្លើយ គេសួរឌីទៀតៈ

«តែបើថាឯងខ្លាច សារភាពមកអា Hacker Level មត្តេយ្យ!»

«អញមិនខ្លាចអាណាទាំងអស់ លើកលែងតែវានោះមិនប្រើ Internet! Bye! អញត្រូវការរកសមាសភាពអាអ្នកបន្លំលិខិតអញ្ជើញ!»

គេដឹងថា Hacker ប្រញាប់ Hack ទិន្នន័យប្រភពអ្នកដែលផ្តល់ទីតាំងសមោសរពណ៌ព្រះចន្ទចុងក្រោយឲ្យមកផានូនេះ។

ចិត្តនាយស័ក្តិបួនចិត្រា ស្រាប់តែនឹកបារម្ភ។

ភាគទី១៨

គេគិតដល់រឿងជាច្រើន បន្តកន្ទុយគ្នា ពីដើមដល់ពេលនេះ។ គេសួរខ្លួនឯង ប្រសិនបើកម្រិតរបស់ ឯកមាន នៅស្រាលហើយជនល្មើសខាងណោះវាខ្លាំងជាងដូចករណីមហាវីនធ្លាប់ប្រើអ្នកជំនាញថៃ នៅតែស៊ូមិនរួច ចុះបើពេលនេះ សញ្ញាលុកចូលរបស់ឯកមាន ក្លាយជាការវាយស្មៅបង្អើលពស់? ផានូនឹងគេ មិនស្ថិតក្នុងសភាពគ្រោះថ្នាក់ទៅហើយទេ??

គេលេបទឹកមាត់ដែលប្រែទៅជាចត់ ហើយឈប់ម៉ូតូខលត្រឡប់បន្ទាន់ទៅកាន់មិត្ត ប៉ុន្តែ… មិនចូល…

វគ្គ អ្នកណាជាម្ចាស់ការអញ្ជើញក្លែងក្លាយ?

«Lorenzo?»

ដូចការគិតរបស់ឧត្តមសេនីយ៍ ឱត សាម៉ុននាងហៅឮៗ ធ្វើឲ្យអ្នកបរិវារទាំងឡាយដែលនៅអមផ្លូវក្នុងគេហដ្ឋានបុរសអ្នកមានស្តុកត្រូវដកថយ ព្រោះដឹងថាសង្គ្រាមកំពុងត្រៀមនឹងផ្ទុះ។ បុរសនេះហិចហែលក្នុងអាងទឹករបស់គេ ហើយក្រោកឡើងមកវិញពេលឃើញនាងឈរសម្លក់ត្លៃក្បែរមាត់អាង។

គេលើកដៃឈោងយកកន្សែងមកជូតមុខជាមួយសម្តីមិនមើលមុខ៖

«អាម្នាក់នោះ មិនមែនខ្ញុំធ្វើទេ! ឮហើយ ចេញទៅវិញចុះ Rose!»

នាងដឹងថា គេចង់សំដៅករណីធ្វើឃាតលើមហាវីនកាលពីយប់មិញ ប៉ុន្តែនាងនៅមិនទាន់ល្មមអាចវិលទៅវិញបានឡើយ បើសិនមិនទាន់បានដាក់សំណួរ៖

«ខ្ញុំដឹងថាមិនមែនលោកហើយ Loren តែរឿងអញ្ជើញសមោសរម៉ោង៩នៀក?»

គេហាក់ភ្ញាក់ផ្អើល។

ទោះគេធ្វើពើ ឬអត់ នាងនៅតែសង្ខេញសំណួរ៖

«លោកប្រកាសការអញ្ជើញសមោសរក្លែងក្លាយ ដើម្បីយកលេសជួបស្រីៗទាំងអស់នោះ! ខ្ញុំដឹងច្បាស់ណាស់!»

Lorenzo បែរខ្នងគិត ប៉ុន្តែគេគិតចុះឡើងនៅតែមិនយល់។ គេពិតជាត្រូវការចូលរួមសមោសរនោះដើម្បីជួបពួកស្រីៗ អ្នកមានដូចនាងបាននិយាយមែន ប៉ុន្តែសម្ដីនាងហាក់បញ្ជាក់ថា អ្នកណាម្នាក់កំពុងតែហៅភ្ញៀវដោយនាងខ្លួនឯងជាមេពិធីការក៏មិនដឹង។

គេងាកមករក Rose ហើយសួរ៖

«ចង់និយាយថាយប់នេះក៏មានកម្មវិធី ហើយយើងជាពិធីការហ្នឹងមិនបានធ្វើការអញ្ជើញ?»

នារីផ្ទង់សម្លឹងគេទាំងមមៃគិត….. តើគេនេះកំពុងធ្វើពើ ឬមួយពិតជាមិនបានជាប់ទាក់ទងមែន? បុរសអាណិកជន គេក៏កំពុងផ្ដោតសម្លឹងមកនាងវិញដូចគ្នា ហាក់បីដូចជា គេកំពុងរង់ចាំការឆ្លើយតប។

រូបនាគពណ៌ក្រហម នៅលើទ្រូងគេ ធ្វើឲ្យនាងទ្រឹងភ្នែកជាប់ទីនោះ។

វាជាប្រភេទស្នាមសាក់ដែលចោមព័ទ្ធដោយភាសាបុរាណសំស្ក្រឹត។ ឃើញភ្នែកនាង Lorenzo ដឹង ពីអ្វីដែលស្រីស៊ីវិល័យកំពុងពិនិត្យ ដូច្នេះបុរសអាណិកជន ងាកចេញហើយទាញព័ទ្ធកន្សែងជុំវិញស្មាដើម្បីបិទបាំង។

Rose ដកភ្នែកមកវិញហើយនាងនិយាយខ្លីៗ៖

«មហាវីនក្រោកមិនទាន់រួចទេ សមោសរគ្មានអ្នករៀបចំផង ហេតុអីមានភ្ញៀវទទួលបានការអញ្ជើញយប់នេះ!?»

Lorenzo ច្រត់ចង្កេះតវ៉ា៖

«ឃើញហើយ! ខ្ញុំនៅទីនេះ មិនបានចេញទៅណាទេ! តើខ្ញុំទៅជួបស្រីៗណាទៅ?»

នាងរិះគិតលើសម្ដីគេដែលសមហេតុផល ប៉ុន្តែរូបនាគលើទ្រូងគេនៅតែចាក់ដោតចិត្តនាងឲ្យតវ៉ា។ Rose និយាយរ៉ាវ៖

«លោកអាចចាប់ពួកគេលាក់ទុក! អ្នកណាដឹង?»

បុរសខ្មែរសញ្ជាតិអាមេរិកថ្លោះទឹកមុខ។ គេនិយាយទាំងខឹងស្លេក៖

«នាងបារម្ភពីអាកន្ទាត់ហ្នឹងឡើងឆ្កួតខ្លួនឯងហើយ Rose !»

Rose តាមមើលមុខនាយ។ នាងដឹងថានេះជាឱកាសដើម្បីឈ្លេចឲ្យដឹងអ្វីទៅសអ្វីទៅខ្មៅ។

ស្រីស្អាតខាំមាត់និយាយ៖

«លើលោកនេះ គ្មានមនុស្សស្រីអច្ឆរិយទាំង៣៥នាក់ទេ! ឈប់ឆ្កួតនឹងរឿងអប្បិយជំនឿអស់ទាំងនោះទៅ! Lorenzo!»

បុរសមាំទាំម្នាក់ដែល មានបង្កប់ពីក្រោយនូវអាថ៌កំបាំងជ្រៅនិងគួរឲ្យចម្លែកបែបនេះរឿងអីថាមិនភ្ញាក់ផ្អើល មិនខឹងសម្បារ ពេលត្រូវអ្នកផ្សេងដឹងអស់ផ្ទៃក្នុង ហើយហ៊ានមកឈរបកអាក្រាតបានគេចំៗរបៀបនេះ។

គេបើកភ្នែកទាំងគូដែលក្រហមដោយកំហឹង សម្លឹងស្រីម្នាក់នៅចំពោះមុខ ព្រោះមិនច្បាស់ខ្លួនឯងឡើយថា តើរឿងអ្វីខ្លះទៀតរបស់ខ្លួនដែលត្រូវបាននាងស៊ើបដឹង ហើយនាងដឹង វាបានដោយវិធីណា?

«និយាយស្អីខ្លះហ្នឹង Rose?»

គេខ្សឹបសួរទាំងខាំមាត់ខឹង។

នាងដឹងថាខ្លួនជ្រុលមាត់។ Loenzo មិនមែនមិនដឹងទេថា Roseស្រលាញ់គេ រហូតដល់តាមដានគេជានិច្ច ហើយបារម្ភជានិច្ចថាតើគេនៅពីក្រោយការបាត់ខ្លួននារីៗអភិជនទាំងអស់នោះដែរអត់? រហូតដល់ពេលម្សិលមិញ មហាវីនមានបញ្ហា នាងបានសម្រេចចិត្តជួលអ្នកជំនាញឲ្យរកប្រវត្តិគេនិងសកម្មភាពLorenzo នៅភ្នំពេញទាំងអស់មកបញ្ជាក់ឲ្យច្បាស់ ថាអ្នកដែលនាងកំពុងស្រលាញ់ជាឧក្រិដ្ឋជន ប៉ូលិសតាមរកដែរ ឬអត់នោះ?

ទោះការស៊ើបមិនអាចដឹងថាគេបានពាក់ព័ន្ធនិងការបាត់ខ្លួនរបស់នារីទាំងបួន តែនាងក៏អាចរកឃើញ ដឹងការពិតខ្លះរបស់គេនិងគោលដៅដែលគេមកភ្នំពេញ ព្រមទាំងចំណាយប្រាក់សន្ធឹកសន្ធាប់ក្នុងនាមជាតារាសប្បុរស និងជាSponsor ធំរបស់សមោសរពណ៌ព្រះចន្ទ។

ពីកន្ទុយភ្នែកឆ្វេងRose ប្រទះឃើញស្រមោលអ្នកណាម្នាក់នៅលើបលក្បែរគុម្ពផ្កា។ នារីនេះដកអារម្មណ៍ចេញពីគំនិតដែលមុននេះគិតថាចង់ជជីកសួរគេរកការពិត ហើយមកភ្ញាក់ខ្លួនវិញថា គ្រោះថ្នាក់នៅកៀកបង្កើយ។

Lorenzo ដែលបោះជំហានចូលមកសន្សឹមៗ ធ្វើឲ្យ Rose ដកថយក្រោយដោយមិនដឹងខ្លួន។

នាងឃើញបុរសនេះកំពុងប្រើកែវភ្នែកដែលមានអត្ថន័យចង់ជជីកសួរនាងនូវសំណួរមួយចំនួនពិសេសគឺថា ហេតុអ្វីបានជានាងអាចនិយាយរឿងចម្លែកៗអស់ទាំងនេះចេញមកបាន?

មេពិធីការចាប់ផ្ដើមរកច្រកគេច.... តែ Lorenze ឈោងមកចាប់ដៃនាងបាន។

គេចាប់ផ្ដើមសង្ខេញសួរ៖

«នាងតាមដានដឹងរឿងខ្ញុំស្អីខ្លះ Rose?»

ពិធីការរបស់មហាវីនដឹងថា ខ្លួនចង់ទៅណាទាំងកណ្ដាលទីមុនការបកស្រាយប្រាកដជាចេញមិនបានដាច់ខាត តាមមើលស្ថានភាពទឹកមុខអាណិកជននេះ។

នាងក៏នៅស្ងៀមលែងរើ ហើយតាមដានទឹកមុខគេជាប់ថាគេចង់ធ្វើយ៉ាងណា?

កែវភ្នែកបុរសនេះត្បិតតែមាំម៉ឺងម៉ាត់ តែមិនមែនសាហាវឃោរឃៅនោះទេ ហេតុអ្វីយើងខ្លាចគេ?

នាងនិយាយពាក្យទាំងនេះ ក្នុងសតិខ្លួនឯងហើយចាប់ផ្ដើមវាចា៖

«លោកមិនមែនអ្នកតាមសម្លាប់មហាវីនទេ ខ្ញុំដឹង! តែលោកមានរឿងអាថ៌កំបាំងជាច្រើនជាមួយស្រីៗទាំងនោះមុនបាត់ខ្លួន! ប្រសិនប៉ូលិសស៊ើបមើល អ្នកដែលត្រូវជាប់សង្ស័យបន្តគឺលោក Loren!»

គេនៅស្ងៀមធ្មឹងសម្លឹងនាងមុនពេលលែងដៃនោះវិញ។ ចិត្តបុរសនេះ កំពុងមិនស្រណុកមែន នាង ដឹង។ នាងនិយាយបន្ថែម៖

«ខ្ញុំមកនេះ ចង់ប្រាប់ថា បើកម្មវិធីក្លែងក្លាយយប់នេះលោកជាអ្នករៀបចំ ឆាប់បញ្ឈប់វាភ្លាម ព្រោះមុននេះមហាវីនខលមកសួរខ្ញុំ ហើយខ្ញុំដឹងថាប៉ូលិសនៅក្បែរគេ!»

Lorenzo នៅពិចារណាចុះឡើងមុនពេលដាក់សំណួរ៖

«នាងប្រាប់ប៉ូលិសអស់ហើយ រឿងដែលខ្ញុំបានជួបស្រីៗអស់ទាំងនោះ?»

នាងគ្រវីក្បាល៖

«លោកដឹងហើយ ថាខ្ញុំមិនធ្វើបាបលោកទេ!»

គេហាក់ធូរចិត្ត ប៉ុន្តែនាងនិយាយបង្ហើយ៖

«តែមហាវីន! ខ្ញុំមិនធានាទេ! គេប្រាកដជានិយាយ! ពេលនេះគេនៅក្នុងដៃប៉ូលិស អ្វីដែលអាចបំផ្លាញលោកបាន ខ្ញុំជឿថាគេមិនខ្លាចនឹងរាយការណ៍ទេ!»

«ហេតុអ្វីនាងប្រាប់វា?»

គេគំហកទាំងមួហ្មង។

នាងនិយាយវិញទាំងឆ្ងល់ហួសចិត្ត៖

«ចង្អេរបាំងខ្មោចដំរី លោកដែលឮថាវាជិតអត់? លោកណាត់ជួបពួកគេបន្ត មុនពេលបាត់ខ្លួន លោកស្មានថាខ្ញុំមិននិយាយ មហាវីនជាថៅកែកម្មវិធីគេមិនដឹង? នៅជុំវិញគេមានតែខ្ញុំម្នាក់?»

គេទើបនឹងដឹងថាស្រីម្នាក់នេះ មកទីនេះទាំងទទឹងទិស ព្រោះបារម្ភពីគេ ប៉ុន្តែគេខ្លួនឯងទេ ដែលមានរឿងជាច្រើនអាចត្រូវជាប់អន្ទាក់។ ទោះបីយ៉ាងណានាយនៅតែមិនព្រមទទួលស្គាល់ដោយចចេសបដិសេធ ព្រមទាំងទាញដៃ Rose ទៅជ្រុងម្ខាងហើយក្រឡេកឆ្វេងស្តាំ មុនពេលខ្សឹបដាក់ត្រចៀក៖

«សូម្បីតែទិន្នន័យក្នុង Internet របស់ស្រីៗអស់នោះត្រូវខ្ញុំលុបចោលអស់គ្មានសល់ដាន រឿងអីថា មានទេវតាណាអាចដឹងបានពីការណាត់ជួបនោះទេ!»

Rose ខ្សឹបប្រាប់បុរសនេះវិញ៖

«លោកចាំទុកពាក្យមួយ Lorenzo គ្មានអ្នកណាពូកែជាងគេលើកលោកនេះទេ ភ្នំមួយខ្ពស់តែងមានមួយទៀតខ្ពស់ជាង! បើមានអ្នកណាម្នាក់ កំពុងតែរៀបចំផែនការអាក្រក់ ឲ្យសមោសរពណ៌ព្រះចន្ទត្រូវចប់ វាទំនងជាមិនសូវអីទេ តែបើគេរៀបចំឲ្យលោករងអន្ទាក់រឿងចាប់ជំរិតមនុស្សស្រី លោកប្រហែលជាយ៉ាប់ចេញពីស្រុកខ្មែរហើយ!»

គេរវើ្តកគិត។ នៅក្រោមភាពងងឹត កែវភ្នែកភ្លឺចិញ្ចាចរបស់គេដែលសម្លឹងមកនាងប្រៀបបីដូចជា បង្ហាញស្រេចហើយថាការគិតរបស់នាងកំពុងធ្វើឲ្យគេភ្ញាក់ខ្លួន។

នាងខ្សឹបស្រាលជាងមុន៖

«ប្រយ័ត្នពួកមនុស្សនៅក្បែរៗលោក!»

«ហេតុអី? វាធ្វើដើម្បីស្អី!»

«ខ្ញុំមិនដឹងទេ! ខ្ញុំយល់ថា វាធ្វើឲ្យមហាវីនសង្ស័យលោក ចំណែកលោកជាប់រឿងស្រីៗប្អូននាក់នោះ! តើចុងក្រោយអ្នកណាចំណេញ ខ្ញុំអត់ដឹងទាំងអស់ ខ្ញុំដឹងតែថាលោកដូចជាកំពុងជាប់អន្ទាក់ជ្រៅជាងគេ!»

សាជាថ្មី Lorenzo ហាក់កាន់តែឆ្ងល់ឆ្ងា។ គេលែងដៃនាងហើយនិយាយតស៊ូ៖

«ខ្ញុំមិនបានចាប់ពួកស្រីៗអស់ទាំងនោះទេ! នាងទេដឹងចូលដៃជាមួយអាមហាវីន ដាក់បន្ទុកលើខ្ញុំ! ខ្ញុំខំទុកចិត្តទុកនាងជាមិត្តម្នាក់ Rose!»

«ខ្ញុំស្រលាញ់លោក ជំនិត វីរៈ!»

នាងហៅឈ្មោះខ្មែររបស់គេ ហើយនាងនិយាយចំមិនបាច់វែងឆ្ងាយ ជាកិច្ចចង់ប្រាប់នាយឲ្យដាច់ស្រេចថា នាងមិនដែលមានសូម្បីតែគំនិតណាអាក្រក់មួយចំពោះគេ កុំថាឡើយឲ្យមកទ្រុស្តគេ ជាមួយអន្ទាក់អស់ទាំងនោះ។

Rose ថាចប់ក៏បែរខ្នងចេញទៅ ព្រោះនាងមិនចង់នៅ ឬមួយនាងមានកិច្ចការផ្សេងត្រូវធ្វើបន្តបន្សល់ទុកអាណិកជនខ្មែររូបសង្ហានៅឈរទ្រឹងកណ្តាលចំណោទបញ្ហា។

«កុំទាន់ជឿនាង១០០ភាគរយទាន!»

ជំនួយការរបស់គេ ឈ្មោះវឌ្ឍនៈចេញមកពីក្រោយគុម្ពផ្កា ជាមួយខោអាវថ្មីលើដៃ។

ជននេះចូលយកខោអាវមកជូនចៅហ្វាយផ្លាស់ ប៉ុន្តែអាណិកជនដឹងថា គេប្រាកដជាបានឮ បានឃើញគ្រប់យ៉ាងដែលស្រីប្រុសទាំងទ្វេចរចាមុននេះ។ បើមិនអ៊ីចឹង ម្តេចក៏គេកាត់សាញ ចៅហ្វាយប្រុសជាមួយនឹងពាក្យមួយឃ្លានេះ?

ទោះបីយ៉ាងណាកាយវិការ Lorenzo ហាក់បីដូចជានៅតែមិនអស់ចិត្ត បានជាជនជំនិតត្រូវតែនិយាយបន្ថែម៖

«នាងអាចជារនុករបស់ប៉ូលិសផងក៏ថាបានទាន!»

«Rose មិនមែនអ៊ីចឹងទេ!»

គេនិយាយផងប្រញាប់ស្លៀកពាក់ផង។

ទឹកមុខវឌ្ឍនៈស្មើ ពេលដែលឃើញប្រុសស្រីទាំងទ្វេសម្តែងការដឹងចិត្តគ្នាច្បាស់កម្រិតនេះ។

គេមិនទាន់ចាត់ការយ៉ាងណាផង ក៏ឮអាណិកជននិយាយបន្ថែម៖

«អូ! ចប់ហើយ!»

Lorenzo រៀបចំចាកចេញបន្ទាន់ បន្ទាប់ពីបានភ្លាត់មាត់។ ភាពប្រញិបប្រញាប់របស់គេធ្វើឲ្យវឌ្ឍនៈរត់តាមប្រដេញសួរ៖

«មានរឿងអីទាន? លោកប្រុសតូចប្រញាប់ទៅណា?»

Lorenzo ដើរជាមួយជំហានវែងៗរបស់គេផងនិយាយផង៖

«បើអ្វីដែល Rose ទើបតែសន្និដ្ឋានហ្នឹងជាការពិត! នាងអាចនឹងមានគ្រោះថ្នាក់ហើយប៉ូលិសនឹងទម្លាក់កំហុសមកលើខ្ញុំ!»

គេបើកថតតុទាញយកសម្ភារៈខ្លះ ក្រោមការឈរទ្រើងតាមសម្លឹងរបស់ជំនួយការ។

វគ្គ ដងផ្លូវងងឹត

Lorenzo ចេញមកដល់រថយន្ត ទាំងដៃនៅកាន់ទូរស័ព្ទចុចទៅរកនាងផង ដៃម្ខាងចុចបញ្ជាបើកទ្វាររថយន្តផង។

«ខ្ញុំបើកជូនវិញ!»

ជំនួយការគេប្រញាប់បើកទ្វារខាងក្រោយជូន ហើយខ្លួនឯងឡើងទៅកន្លែងខាងមុខ។

«ទៅណាទាន?»

«ទៅផ្ទះ Rose! ទូរសព្ទមិនចូលទេ!»

រថយន្តបញ្ជាលឿនស្លេវលើផ្លូវងងឹតស្ងាត់។

ហេតុអីក៏រាត្រីនេះរាជធានីភ្នំពេញដូចជាខ្មៅងងឹតជាងសព្វមួយដង?

អត់ទេ! គឺមកពីភាពស្មុគស្មាញក្នុងចិត្តរបស់បុរសនេះ។

Lorenzo គិតចុះឡើងនូវពាក្យរបស់នាងប៉ុន្មានម៉ាត់ចុងក្រោយ «ខ្ញុំយល់ថាលោកដូចជាកំពុងជាប់អន្ទាក់ជ្រៅជាងគេ!»។

បុរសអាណិកជនដៀងភ្នែកគិត។ គេលើទូរស័ព្ទមកចុចមើល។ រូបថតខ្លួននិងបុរសម្នាក់ដែលកំពុងតែបង្ហាញលើអេក្រង់ធ្វើឲ្យចិត្តគេហេងហាង៖

«ប៉ា! កូនប្រុសប៉ាម្នាក់នេះពិតជាដើរតាមគន្លងចាស់របស់ប៉ាមកចាញ់ល្បែងឆ្លិនភ្នែករបស់ពួកមនុស្សនៅភ្នំពេញមែនឬអ្វី?»

សំឡេងជំនួយការលាន់មកពីបាំងខាងមុខ៖

«លោកមេធាវីទូរសព្ទមកពីអាមេរិក សួរនាំពីរឿងលោកប្រុសតូច! គាត់ឲ្យខ្ញុំតាមដានលោកប្រុសតូចឲ្យបានគ្រប់ជំហាន!»

«ខ្ញុំមិនមែនក្មេងទេ!»

គេឆ្លើយខ្លី តែចិត្តវិញកំពុងហោះហើរវែងឆ្ងាយ។

ម្ដងម្កាលគេធ្លាប់ឮអ្នកជិតដិតនាំគ្នារំលឹកពីរឿងសំណុំ Folder Z22 ដែលឪពុកខ្លួនធ្លាប់ជាប់ផុងសឹងថាបាត់បង់ដល់ជីវិតសង្ខារ គ្រាន់តែថាគេមិនដែលហ៊ានសួរនាំព្រោះនោះជារឿងដែលចាស់ៗចង់កប់ឲ្យបាត់ចោលទៅតាមពេលវេលា។

តើមានឪពុកណាមួយសប្បាយចិត្តទៅនៅពេលដែលត្រូវកូនសួរនាំអំពីរឿងចាស់ដែលជាប់ស្នាមដោយសារការប្រចណ្ឌមិនទុកចិត្តភរិយា។ Lorenzo កូនប្រុសតែម្នាក់គត់ដែលមានទ្រព្យសម្បត្តិចាយច្រើនជាតិទៅមុខក៏មិនអស់ តាំងពីអាមេរិកមកដល់ដីកម្ពុជា គេក៏មិនដែលគិតថា ខ្លួនចូលអន្ទាក់អ្នកណាម្នាក់នោះទេ។

គេទម្លាក់ទូរសព្ទចុះក្រោយពេលដែលការព្យាយាមច្រើនដងនៅតែទាក់ទងមិនបានសម្រេច។

ដៃនាយចុចសារទៅរកនាងខ្លីៗក្នុងន័យបារម្ភ៖

«ប្រយ័ត្នខ្លួន! សភាពការណ៍មិនល្អប៉ុន្មានទេ! បើចាំបាច់ មកនៅខាងខ្ញុំមួយរយៈសិនក៏បាន!»

គេដាក់ទូរសព្ទចុះ ហើយនិយាយរអ៊ូ៖

«មនុស្សស្រីចិត្តខ្លាំង! ទើបតែនិយាយគ្នាមិនបានអីផងបាត់ស្រមោលភ្លាម!»

«លោកប្រុសតូចស្រលាញ់ Rose?»

មនុស្សជំនិតសួរឆ្កុយមកធ្វើឲ្យគេងើបមុខសម្លឹងទៅវិញតាមកញ្ចក់។ គេមិនបានសួរអ្វី ក្រៅពីចោលពន្លឺភ្នែកទៅ តែនាយជំនួយការនិយាយបន្ថែមមកទៀត៖

«លោកប្រុសតូចមានអាការបារម្ភប្លែក!»

Lorenzo សើចខឹកៗ។

ស្នាមញញឹមស្រស់សង្ហាដ៏កម្ររបស់គេ ប្រាកដណាស់ស្រីណាឃើញមិនគេចពីយកទៅគិតពេញមួយយប់នោះឡើយ ចៃដន្យអីបុរសនេះសើចតែជាមួយមនុស្សក្នុងគ្រួសារគេតែប៉ុណ្ណោះ។

«បងឯង មិនទាន់ស្គាល់អ្វីហៅថាស្នេហាទេអ៊ីចឹងនោះ!»

គេថាឲ្យមនុស្សជិតដិតម្នាក់នេះ ទាំងខ្លួនឯងក៏មិនដឹងដែរថាធ្លាប់ចេះស្រលាញ់ដែរអត់ តែគេប្រាកដណាស់ ក្នុងបេះដូងគេគ្មាន Rose នោះទេ។

សេចក្តីបារម្ភនេះមានលក្ខណៈពុះពោរ ព្រោះនាងជាមនុស្សដែលគេយល់ថា «ល្អ» នាងគិតពីគេ បារម្ភពីគេ នាងជាមនុស្សស្រីបើកចំហ ហើយឯកោ... គឺហេតុផលតែប៉ុណ្ណឹង។

គេឈប់គិតពីសម្ដីរបស់មនុស្សក្បែរខ្លួន ហើយមកនិយាយរឿងសំខាន់ចំពោះមុខវិញ៖

«បើមហាវីន ដេកពេទ្យទៅហើយ តើមានអ្នកណាដែលអាចមកកោះហៅសមោសរក្លែងបន្លំទៅកើត!»

គេសួរតិចៗទៅតាមចិត្តបាចហាច ដឹងអីជំនួយការឈ្មោះវឌ្ឍនៈតបវិញមួយរំពេច៖

«ហើយម្នាក់ហ្នឹងដដែលដែលជាអ្នកចាប់ស្រីៗអស់ទាំងនោះ!»

អ្នកបើកបរនេះ និយាយធូរតពីនាយ តែLorenzo យល់ថា សម្ដីគេដូចអ្វីដែលអ្នកកំពុងទទួលស្គាល់ពិតណាស់។

គេនៅស្ងៀមម្ដងម្កាល ងើបភ្នែកសម្លឹងអ្នកបើកបរជំនិតនេះធ្វើឲ្យនាយវឌ្ឍនៈបន្តមកទៀត៖

«អាហ្នឹង បើពិតដូចសម្ដីអ្នកនាង Rose មែន!»

គេស្ដាប់ហើយកាលណា ងាកសម្លឹងផ្លូវវែងអន្លាយដែលរត់ថយក្រោយ ដូចជាអាថ៌កំបាំងនៃរាត្រីកាលនៃរាជធានីដ៏ចំណាស់មួយ ដែលគ្មានអ្នកណាដឹងបានថាមានជនគំនិតមិនល្អណាកំពុងសំងំធ្វើអ្វីខ្លះ ហើយគេចាប់នារីៗទាំងនោះយកទៅណាក្នុងបំណងបែបណា?

គេនឹកឃើញអ្វីម្យ៉ាង ក៏បន្ទូរសំឡេងនិយាយខ្សាវៗទៅកាន់អ្នកជំនួយការ៖

«ម៉េច Rose ដឹងរឿងមនុស្ស ស្រីអច្ឆរិយទាំង៣៥នាក់នោះដែរ?»

បរិយាកាសស្ងាត់ស្ងៀមគ្មានចម្លើយ។ Lorenzo ដឹងថាសំណួររបស់គេ ដែលគេខ្លួនឯងក៏គ្មានចម្លើយ ពេលនេះបាននឹងកំពុងធ្វើឲ្យវឌ្ឍនៈរកឆ្លើយអ្វីមិនបានដូចគ្នា។

«បត់ចូលបុរីហ្នឹងទៅ!»

«អូខេ!»

រថយន្តទំនើបហួសរបស់នាយ ធ្វើឲ្យសន្តិសុខរត់មកគំនាប់។

«រកអ្នកណាដែរទាន?»

«អ្នកនាង Rose!»

«គាត់មិនទាន់មកវិញទេទាន!»

សាជាថ្មី គេរវេភ្នែកសម្លឹងអ្នកជំនិតនៅបាំងខាងមុខ។

«ខ្ញុំសុំចូលរង់ចាំបានអត់បង?»

វឌ្ឍនៈសួរធ្វើឲ្យសន្តិសុខរារែក។

ឋានៈ កាយវិការសុភាពរាបសាររបស់ពួកគេពិបាកឲ្យអ្នកណាបដិសេធបានណាស់ដូចដឹងស្រាប់។

«អញ្ជើញ!»

សន្តិសុខថយបណ្ដោយឲ្យរថយន្តលូនសន្សឹមៗចូលទៅខាងក្នុង។

«ផ្ទះលេខ១១!»

សន្តិសុខពោលប្រាប់បន្ថែម ធ្វើឲ្យអ្នកបើកបរញញឹមរាដៃជាសញ្ញាអរគុណហើយឆ្ពោះជំនិះទៅរកគោលដៅ។

តំបន់នេះស្ងាត់សូន្យដូចគ្មានអ្វីចម្លែក ព្រោះវាប្រមូលផ្ដុំទៅដោយភូមិគ្រឹះធំៗ។ ផ្ទះតូចជំទើររបស់នាង ក៏មិនមែនមានតម្លៃក្រោមកន្លះលានដែរក្នុងផ្សារអចលនៈទ្រព្យខ្មែរ។ គេចុះពីជំនិះហើយងើបមុខសម្លឹងទៅខាងក្នុងផ្ទះ។ របងមិនបានបិទ រីតតែឆ្ងល់ដែលភ្លើងខាងក្នុងមានបើកខ្លះដែរ។

ដោយជ្រួញចិញ្ចើមឆ្ងល់ Lorenzo ដើរមួយៗទៅក្បែរទ្វារហើយប្រើដៃរុញបម្រុងនឹងចូល។

«កុំចូលទាន!»

វឌ្ឍនៈក្រោកមកពីក្រោយខ្នង។ សម្ដីគេអាចបង្អាក់ដៃនាយ តែនាយនៅតែចង់ចូលទៅនេះបើតាមការយល់ឃើញរបស់មនុស្សជំនិត។ អ៊ីចឹងហើយជំនួយការប្រាប់ខ្សឹបប្រាប់៖

«នៅស្រុកខ្មែរ ចូលផ្ទះគេថ្មើរណោះមិនសមទេ ម្ចាស់គេក៏មិននៅ!»

អាណិកជននៅទ្រឹងទាំងដកដង្ហើមធំ។

គេនៅឈរស្ងៀមទ្រឹង រង់ចាំស្ដាប់យោបល់មនុស្សក្រោមបង្គាប់។ នៅទីនេះ កណ្ដាលទីក្រុងនេះ គេទុកចិត្តតែបុរសនេះម្នាក់ ចុះហេតុអីពេលនេះគេចេះតែមានអារម្មណ៍ថាខ្លួនឯងធ្វើខុសចំពោះនារីម្នាក់ ដែលកន្លងមកតែងតែល្អចំពោះខ្លួន ហើយពេលនេះទៀតនាងហាក់ដូចជាធ្វើឲ្យគេ មានអារម្មណ៍ថា ការនិយាយគ្នាអម្បាញ់មិញនេះជាការនិយាយគ្នាចុងក្រោយ?

ភ្លៀងធ្លាក់រិចៗ... គេហាក់មានអារម្មណ៍ត្រជាក់។

«ចូលក្នុងឡានវិញក៏បាន!»

សម្ដីជំនួយការពេលនេះប្រែទៅជាគ្មានបានការទេ ព្រោះថានាយកំពុងតែផ្ដោតភ្នែករំពៃទៅរកអ្វីម្យ៉ាងកំពុងមានស្ថានភាពខាងក្នុងផ្ទះ។ Lorenzo ពេលនេះគេប្រាកដក្នុងចិត្តណាស់ គេបានឃើញរបស់មានជីវិតកម្រើកមួយប៉ប្រិចភ្នែកអម្បាញ់មិញ ហើយពិតណាស់គេមិនជឿថាខ្លួនឯងបានមើលច្រឡំទេ។

«ខាងក្នុងមានមនុស្សតើវឌ្ឍនៈ!»

គេនិយាយខ្សឹបៗប្រាប់ជំនួយការឲ្យបបួលគ្នាតាមដានមើល។ ពេលវឌ្ឍនៈពិតជាផ្ទៀងមើល Lorenzoបោះជំហានចូលទៅមួយៗ ភ្នែកគេក៏ក្រឡេកមើលឆ្វេងស្ដាំក្រែងឃើញរថយន្តរបស់នាង។

«Rose?»

គេហៅសួរតិចៗ តែល្មមអាចឮដល់ខាងក្នុង ព្រោះបរិយាកាសនៅទីនេះស្ងាត់ច្រៀប។

ភាគទី១៩

មិននឹកស្មានថា សំឡេងមិនទាន់ចប់ គេឃើញស្រមោលធំមួយបោះពួយប្រាវហើយភ្លើងបន្ទប់រលត់វិញភ្លឹប។ ចិត្តនាយតក់ក្រហល់។

ហេតុការណ៍នៅចំពោះមុខបង្ហាញថាមានអ្វីមួយមិនប្រក្រតីកំពុងកើតឡើងពិតណាស់ ទោះបីជា Rose មិននៅខាងក្នុងក៏ម្នាក់ដែលរត់មុននេះអាចជាចោរ ឬអ្នកណាម្នាក់កំពុងតែមានបំណងមិនល្អចំពោះម្ចាស់ផ្ទះ។

«អ្នកណា?»

គេស្រែកសួរភ្លាមហើយតាមសម្លឹងស្រមោលនោះ។

មនុស្សម្នាក់នោះរហ័សដូចផ្លេកបន្ទោរ ផ្លោះរបងចេញទៅបាត់ ក្រោមកែវភ្នែកស្រឡាំងកាំងរបស់ថៅកែនិងជំនួយការ។ មិនដឹងត្រូវធ្វើយ៉ាងណា វឌ្ឍនៈចាប់ផ្តើមដាស់តឿន៖

«យើងកុំចូលទៅ ក្រែងមានរឿងជាន់ដានគេ!»

សម្តីរបស់វឌ្ឍនៈ បង្ហាញថាគ្រប់វិនាទីគ្រប់កាលៈទេសៈ គេចិញ្ចឹមចិត្តប្រុងប្រយ័ត្នជានិច្ចចំពោះសុវត្ថិភាពរបស់មេកោយម្នាក់នេះ មិនមែនព្រោះជំនិតឪពុករបស់Lorenធ្លាប់ជាប់ស៊ងគេកាលពីប៉ុន្មានឆ្នាំមុននៅស្ទឹងហាវ ធ្វើឲ្យគេរាងចាលប៉ុន្តែ សភាពការណ៍មនុស្សមាឌធំផ្លោះរបងជាសកម្មភាពអកុសលច្រើនជាងប្រផ្នូលល្អ មានហេតុផលអីត្រូវឲ្យលោកប្រុសតូចរបស់ខ្លួនទៅប្រថុយ?

Lorenzo នៅតែរំពៃពិនិត្យចុះឡើង ជុំវិញសួនធ្វើឲ្យគេប្រញាប់និយាយតឿនបន្ថែមទៀត៖

«លោកប្រុសតូច! យើងទាក់ទង Rose បានសិនចាំគិតទៀត!»

គេមិនឆ្លើយអ្វីនឹងសំណើនេះ បែរជាចង្អុលប្រាប់៖

«បងឯងឃើញរបស់នោះអត់?»

តាមចង្អុលដៃគេ វឌ្ឍនៈសម្លឹងទៅរកគោលដៅទាំងចិត្តបារម្ភ។ គេពិតជាឃើញអ្វីមួយគួរឲ្យទាក់ភ្នែក កំពុងដេកស្ងៀមលើស្មៅក្បែររបង។

គ្រាន់តែសម្លឹងពីចម្ងាយ ក៏អាចស្មានដឹងពីទម្ងន់វាដែលជាដើមចមឲ្យជនម្នាក់អម្បាញ់មិញមិនអាចយកវាឡើងតាមរបងបាន បានជាត្រូវបង្ខំចិត្តទម្លាក់ចោលនៅទីនេះ។

«របស់ស្អីហ្នឹង?»

Lorenzo និយាយផងឈានជើងទៅក្បែរផង។

«កុំប៉ះ!»

ជំនួយការដ៏ប្រយ័ត្នប្រយែង និយាយឃាត់សាជាថ្មីតាមចរិតប្រុងប្រៀបមិនប្រហែសរបស់គេប៉ុន្តែឥទ្ធិពលគេតិចជាងវត្ថុនោះ។ ពេលនេះគេលើកវាមកពិនិត្យក្នុងដៃរួចទៅហើយ។

វឌ្ឍនៈឈានចូលមកជិតប្រុងបបួលលោកប្រុសតូចចេញ ប៉ុន្តែគេខ្លួនឯងក៏ត្រូវវត្ថុនោះទាក់ចិត្តឲ្យសម្លឹងមើលទាំងចំហមាត់ផ្លុងដែរ។

Loren វត្ថុបុរាណភ្លឺរលោងមកផ្សៀងផ្អងចុះឡើងរួចផ្អាប់ពិនិត្យបាតរបស់វា។

«ថាមែនៗ អាម្នាក់មិញចូលមកលួចរបស់មានតម្លៃសោះ! ម៉ាអាចោរ!»

វឌ្ឍនៈនិយាយទាំងងើបមុខសម្លឹងរបងផ្ទះ ដែលមិនសមថាខ្លួនមកទាន់អាចការពារឲ្យចោរកំហូចរត់ចេញស្លន់ស្លោមិនអាចយកវត្ថុដែលវាប៉ងនោះបាន។

«ក្លែងក្លាយហ្នឹង!»

Lorenzo ឆ្លើយធម្មតា ប៉ុន្តែវឌ្ឍនៈងាកមកវិញភ្លាមសម្លឹងថៅកែរួចឈ្ងោកសម្លឹងរបស់។

ម្ចាស់ប្រុសទម្លាក់វត្ថុនោះមកលើដៃជំនួយការ ហើយរលាស់បោសដៃនិយាយ៖

«ស្រុកខ្មែរ របស់អាម៉េចក៏ក្លែងធ្វើកើតដែរហ្ន៎! ប៊ិនម៉េះ? ធ្វើតាំងពីរបស់រាជវង្សឥណ្ឌាឡើង!»

វឌ្ឍនៈសម្លឹងស្នាដៃសិល្បៈឆ្លាក់ដ៏ល្អឥតខ្ចោះក្នុងដៃខ្លួន។ នេះបើកុំតែព័ត៌មានចេញពីមាត់អ្នកដែលខ្លួនស្គាល់ សមត្ថភាពច្បាស់គេមិនជឿឡើងថាចូក្ខរស្រូវដ៏ស្រស់ប្រណីតនេះជាវត្ថុក្លែងបន្លំ។

វាស្អាតដល់ថ្នាក់ជំនួយការប្រុងទម្លាក់ចោលវិញ កុំឲ្យមានរឿងដល់ខ្លួន តែគេនៅតែមិនដាច់ចិត្ត នៅតែពិនិត្យវាចុះឡើង...

ស្នូរឡានឈប់ង៉ឹតនៅខាងក្រៅរបង...

សំឡេងតក់ក្រហល់របស់វា ហាក់បីដូចត្រូវបានគេបង្ខំជាន់ហ្វ្រាំងពេញទំហឹងផ្អើលមេឃ ហើយស្នូរជើងមនុស្សបីបួននាក់លោតចុះមក ធ្វើឲ្យអារម្មណ៍ជំនួយការវិលមកវិញភាន់ភាំង និងក្រុមប៉ូលិសដែលបង្ហាញខ្លួនរហូតដល់វត្ថុចម្លាក់ត្រូវនៅទ្រឹងសំកាំងជាប់លើដៃ។

Lorenzo សម្លឹងទៅក្រុមមនុស្សដែលកំពុងធ្វើមុខមាំសម្រុកចូលមក។ ចង់មិនចង់ គេមានអារម្មណ៍អាក្រក់ភ្លាមមួយរំពេច។

វត្ថុបុរាណនៅលើដៃជំនួយការវឌ្ឍនៈគឺជាគោលដៅនៃការសម្លឹងមកពីគ្រប់គ្នាធ្វើឲ្យគេនោះទីទើរមិនដឹងថាត្រូវដាក់ចុះឬបន្ត កាន់ទៀតនោះឡើយ។

«របស់អីគេហ្នឹង?»

សំឡេងសួរលាន់ឡើងក្នុងចំណោមមនុស្សពាក់ឯកសណ្ឋាន ធ្វើឲ្យក្រសៃភ្នែកជំនួយការម្នាក់នេះដៀងមករកថៅហ្វាយបញ្ចេញភាសាសម្ងាត់ថា «នៅមិននៅ! យើងមកមានរឿងទាល់តែបាន!»។

វគ្គ ប៉ូលិសក្លែងក្លាយ

បរិយាកាសនៅគេហដ្ឋានលោកឧត្តមសេនីយ៍ឱត សាម៉ុន នៅតែស្ងាត់ជ្រងំដូចមិនមានអ្វីប្លែកឡើយ ទោះបីជាល្ងាចនេះគេឃើញមានបញ្ជូនកម្លាំងប៉ូលិសមកថែមមួយឡានទៀតក្ដី។

នៅក្បែរពូហឿន ចិត្រាឃើញពួកប៉ូលិសកំពុងជជែកឆ្ការដៃជើង ជក់ចិត្តជាខ្លាំង សូម្បីអង្គរក្សស័ក្តិបួនអូសម៉ូតូចូលមកហើយនៅតែគ្មានគេងាកមកចាប់អារម្មណ៍សោះ។

«ពូ! ជក់ម៉េះពូ! អ្នកណាលួចចូលក៏មិនដឹងដែរមើលទៅ!»

គេស្រែកសួរលេងពីចម្ងាយ កម្ចាត់ភាពតប់ប្រមល់ ចំណែកពូហឿនញញឹមស្រែកតបមកវិញធ្វើវាហី៖

«អត់ទេ! ពូឃើញក្មួយតើ! ដឹងថាគ្នាឯងបានជាពូមិនធ្វើខ្វល់!»

ទាយដឹងថា ពួកគេកំពុងជក់ចិត្តស្ដាប់ ពូហឿននិយាយពីគំរូវីរភាពប៉ូលិសមុនៗ។

ភ្លាមនោះ ចិត្រានឹកឃើញដល់ពូរបស់ខ្លួន... ឧត្តមសេនីយ៍សេតវិទូដ៏ចំណាប់។

កំលោះដកដង្ហើមធំ អូសម៉ូតូផងរអ៊ូម្នាក់ឯងផង៖

«បើខ្ញុំបានត្រឹម១០ភាគរយលោកពូក៏ល្អ!»

«ក្មួយអង្គរក្ស ក្មួយឃើញអ្នកនាងអមរាជាទេ?»

សំឡេងមីងម៉ាឡា គេស្គាល់ច្បាស់ ប៉ុន្តែកាលដែលសួររកម្ចាស់ស្រីតូច ហាក់បីដូចជាព្រនង់មួយសំពងមកផ្ទង។

តាំងពីមន្ទីរពេទ្យមកម្ល៉េះ គេទាក់ទងនាងមិនបានទេ ខលមកអ្នកផ្ទះក៏គ្មានគេលើក ទើបតែមកដល់ភ្លាមឃើញមានកូនប៉ូលិសនៅស្អេក ក៏ទុកចិត្តលែងបារម្ភខ្វល់ខ្វាយ ដឹងអីថាជើងមិនទាន់ដល់ក្នុងផ្ទះផង ប៉ះសំណួរសឹងលស់ព្រលឹងទៅហើយ។

គេដាក់ម៉ូតូសឹងមិនជាប់ ហើយងើយទៅរកគាត់។ អ្នកម៉ាឡាពេញដោយទឹកមុខព្រួយកង្វល់ ហើយកំពុងរង់ចាំចម្លើយ។

នរៈនៅខាងក្រោមគ្រវីក្បាលភ្លាម ព្រោះមិនចង់ឲ្យគាត់រង់ចាំយូរ។ គេនិយាយឮៗ បកឡើងទៅជាន់លើវិញ៖

«ខ្ញុំទើបមកពីពេទ្យទេមីង!»

ពូហឿនលោសម្ដីមកពីចម្ងាយ៖

«អ្នកនាងនិងលោកជំទាវចេញទៅផ្ទះក្រោយយើងនេះ! អ្នកជិតខាងគ្រេចដៃ លោកជំទាវនិងអ្នកនាងទៅសួរសុខទុក្ខ!!»

ចិត្រាបើកភ្នែកក្រឡង់ៗ សម្លឹងទៅរកពូហឿនដោយបង្ហាញទឹកមុខថា ខ្លួនកំពុងគិតយ៉ាងណា។ ហាក់យល់ចិត្តកំលោះនេះណាស់ដែលកំពុងតែបារម្ភផងបន្ទោសផង។ គាត់ញញឹមលួងចិត្តនាយស័ក្តិបួន៖

«កូនប៉ូលិសពីរនាក់ជូនទៅដែរទេតើ! មិនមែនលោកជំទាវអញ្ជើញទៅតែពីរនាក់អ្នកនាងអមរាជាទេ!»

បុរសនេះអង្គុយចុះ ហើយឈ្ងោកមុខចុចទៅរកឯកមានសាជាថ្មី។

ស្ងាត់ច្រៀបគ្មានចម្លើយតប...

គេចាប់ផ្ដើមរំពៃគិត... តើថ្មើរណោះឯកមាននិងឈុនរាជ ចេញទៅដល់ណា បានជាមិនទាក់ទងគ្នាបាន? គេចាប់ផ្ដើមវាយទៅរកប្រធាននិស្សិតទាបកន្ធៀដ៏ក្លាហានម្នាក់នោះ។

ទូរសព្ទគេនោះ ក៏មិនអាចទាក់ទងគ្នាបានទៀត?

ចិត្រាឱនសម្លឹងទូរសព្ទខ្លួនឯង... ស្រ្តីចំណាស់មកដល់ពីក្រោយខ្នង ហើយវាចាតិចៗ៖

«មីងទើបនឹងមកពីផ្សារ បានជាមិនដឹងរឿងអ្នកផ្ទះក្រោយនេះគ្រេចដៃ! មីងទៅតាមលោកជំទាវសិនក្រែងលោកមានអីប្រើ ក្មួយហៅវបាយ ទៅរកហូបខ្លួនឯងចុះណា នៅផ្ទះបាយ!ឲ្យក្មេងៗចុងភៅដួសឲ្យណា! មីងទៅសិនហើយ!»

«ឈប់សិនមីង!»

មីងម៉ាឡាងាកមកវិញ ហាក់ឆ្ងល់នឹងទឹកមុខស្មុគស្មាញរបស់គេ។

គេអេះអុញមុនដាច់ចិត្តសួរថែមៈ

«មីងមានលេខអ្នកនាងផានូមិត្តរបស់អ្នកនាងអមរាដាដែរ?! គឺលេខទូរសព្ទណាមីង?»

សង្ឃឹមថា គាត់មិនគិតផ្សេងដែលយើងនេះជាអង្គរក្សគេនៅសុខៗហ៊ានថ្លើមពាសមេឃទៅសុំលេខរបស់ស្រីក្រមុំកូនអ្នកមានខុសឋានៈម្នាក់។

ចង់ប្រាប់ហេតុផលថា យើងកំពុងតែនឹកបារម្ភអំពីបេសកកម្មរបស់ឯកមាន រឹតតែមិនអាចហាទៅរួចទៀត តើពេលនេះបើគាត់បន្ទោសគិតតបដោយវិធីណា។

ទោះយ៉ាងណាចាស់ៗក្នុងផ្ទះនេះសុទ្ធតែជាមនុស្សយល់ការ។ គាត់នៅទ្រឹងសម្លឹងមកអ្នកកំលោះភ្លឺះៗពិតមែន តែតាមពិតគាត់ក៏មិនបានកើតក្តីឆេវឆាវថាឲ្យនាយដូចដែលស័ក្តិបួនបាននឹកស្មានស្ងាត់ៗក្នុងគំនិតនោះឡើយ។

គាត់ឱនបើកទូរសព្ទបណ្តើរ មាត់ឆ្លើយតបបណ្តើរៈ

«មីងដូចធ្លាប់មាន Save ទុកតើ!»

ពេលវេលាកន្លងទៅ ការហៅទូរសព្ទទៅកាន់អ្នកទាំងប៉ុន្មានសុទ្ធតែគ្មានបានការ។ គេចាប់ផ្តើមផ្ញើអក្សរទៅឧត្តមសេនីយ៍។

«មិនអាចទាក់ទងឯកមានបានសោះទាន! ព្យាយាមច្រើនដងហើយ!»

លោកឱត សាម៉ុនឆ្លើយតបវិញភ្លែតបង្ហាញថាគាត់មិនបានទៅណាឆ្ងាយពីការតាមដានឡើយ ៖

«ខ្ញុំដឹងហើយ! ឈុនរាជ ផានូសុទ្ធតែបិទទូរសព្ទទាំងអស់! អាចជាវិន័យរបស់កម្មវិធីគេ?»

«បាទទាន! ទទួលបាន!»

«លោកនៅផ្ទះខ្ញុំ?»

«បាទទាន! អ្នកនាងនិងលោកជំទាវចេញទៅផ្ទះអ្នកជិតខាងមុនខ្ញុំមកដល់ទៀត! ខ្ញុំកំពុងរង់ចាំលោកទាំងពីរនៅផ្ទះ! ពូហឿនថាមានប៉ូលិសពីរនាក់ជូនដំណើរទៅ!»

ឧត្តមសេនីយ៍ខលមកហើយនិយាយផ្ដែផ្ដាំបន្ថែមភ្លាមៗ៖

«លោករកបាយទឹកហើយនៅស្នាក់ យប់នេះប្រហែលខ្ញុំរវល់មិនទាន់បានទៅផ្ទះទេ! នៅនុះ Roy គេបានបញ្ជូនប៉ូលិសទៅច្រើនដែរ គេទៅជួយមើលនៅហ្នឹង! ចាំណាំ! គេធ្វើការគេយើងធ្វើការយើង!រឿងកើតឡើងចំពោះមហាវីន និងរឿងរបស់ឯកមានមិនឲ្យនិយាយផ្ដេសផ្ដាសដាក់អ្នកដែលមិនពាក់ព័ន្ធនឹងការកាន់សំណុំរឿងដាច់ខាត ទោះកូនប្រពន្ធខ្ញុំក៏ដោយ!»

«បាទទាន! មិនហ៊ានប្រឆាំងបញ្ជាទេទាន!»

ចប់ការសន្ទនា គេងើបដើរចុះឡើង។

...គ្មានស្រមោលអ្នកនាងអមរាដានិងលោកជំទាវវិលមកវិញ ក្នុងសភាពដែលអង្គរក្សកំពុងទន្ទឹងរង់ចាំដោយអន្ទះសានោះឡើយ។ មីងម៉ាឡាទៅបាត់ម្នាក់ទៀត ហើយក៏មិនឃើញវិលមក តើអង្គរក្សម្នាក់នេះគួរតែទៅតាមដោយមិនមានការហៅដែរទេ?

តួនាទីរបស់ខ្លួនគឺ ការពារកូនស្រីផ្ទះនេះ ប៉ុន្តែដែលត្រូវទើសនោះគឺលោកជំទាវ។ ពេលនេះលោកជំទាវមិនបានអនុញ្ញាតឲ្យទៅជាមួយ ទោះអ្នកណាក៏មិនហ៊ានធ្វើមធំអើតកទៅរកដោយចិត្តឯងដែរ។ ប៉ូលិសបំបែកគ្នាទៅផ្ទះខាងក្រោយ ទំនងជាដល់ពេលបាយទឹកហើយ ពូហឿនក៏កំពុងដើរសំដៅ ទំនងជាមកហៅចិត្រាទៅបាយដែរ តែអារម្មណ៍គេនៅផ្ដោតតែលើរឿងសំខាន់៖

«ផ្ទះដែលមានអ្នករបួសនៅចំពីក្រោយយើងនេះមែនអត់ពូ?»

គាត់ងក់ក្បាល ជំនួសចម្លើយហើយពោលប្រាប់៖

«បាយសិនទៅម៉ោងជិត៨ហើយ!»

គេលើកទូរសព្ទមកមើលម៉ោង។

បើតាមគម្រោង ក្រុមឯកមានគួរតែទៅដល់កន្លែងសមោសរនោះហើយដឹង?

ក្រឡេកទៅពូហឿន គាត់ស្រស់ស្រាយណាស់។ គាត់ជាមនុស្សចាស់ដែលចូលចិត្តជជែកសម្បូររឿងនិយាយមិនចេះខ្វះ ពិសេសឲ្យតែពាក់ព័ន្ធនឹងសំណុំរឿងឧក្រិដ្ឋកម្ម គាត់តាមដានមិនដែលចន្លោះទេ។

លើកនេះទំនងជារឿងថ្មីៗរបស់មហាវីននិងសំណុំរឿងក្មេងស្រីបាត់ខ្លួន គាត់ពុំបានដឹងទេ។ ចំណែកចុងក្រោយនេះទៀត រឿងអ្នកនាងផានូដ៏ស្រស់ស្អាតត្រូវបន្លាយខ្សែចេញទៅធ្វើជានុយរបស់ប៉ូលិស។ ប៉ូលិសក៏ទំនងជាគាត់មិនបានដឹងរឿងដែរ បានជាអ្នកខាងណោះបាយមិននឹកទឹកមិនស្រេក គាត់វិញដើរធូរល្ហុយសប្បាយចិត្ត ដែលឃើញមានប៉ូលិសមកស្នាក់ច្រើននឹងអាលមានគ្នាជជែក។ គេយល់ថា ដរាបណាមេឃកាន់តែងងឹត ចិត្តខ្លួនក៏រឹតតែមិនសូវស្រួលទ្វេឡើង។

សម្ដីលោកឧត្ដមសេនីយ៍លាន់កម្រើកចុះឡើងក្នុងការចងចាំរបស់នាយ៖

«ខ្ញុំចេះតែមានអារម្មណ៍មិនល្អ!» «កូនប្រពន្ធខ្ញុំដាក់ប៉ូលិសទៅថែមហើយ! អមរាដាខ្ញុំមិនឲ្យចេញទៅណាទាំងអស់យប់នេះ!» «ទោះបីជា Roy បញ្ជូនពួកប៉ូលិសទៅយាមកាមនៅផ្ទះ ប៉ុន្តែលោកឃើញហើយវរសេនីយ៍ត្រី! កម្រិតរបស់ចោរ មានប៉ុន្មានគីឡូដែលកំពុងដើរមុនយើង!!»

គេងើបមុខមកសម្លឹងជនចំណាស់ នៅចំពោះមុខខ្លួនហើយនិយាយប្រាប់គាត់ដោយមិនរុញរា៖

«ពូហឿន ខ្ញុំចង់ទៅចាំនៅក្រៅរបងផ្ទះអ្នកដែលគ្រេចដៃហ្នឹង! គឺថា នែក... ខ្ញុំចង់ចាំទទួលអ្នកនាងអមរាដានិងលោកជំទាវវិលមកផ្ទះវិញ!»

ពូហឿនសើចហើយនិយាយឃាត់៖

«អូ! អត់អីទេ! កុំខ្វល់ពេកលោកស័ក្តិបួន! ផ្ទះក្រោយនេះ អ្នកនាងអមរាដាផ្លោះទៅលេងតាំងពីតូចមក! អត់អីទេ ជឿពូទៅ!»

គេក្រោកដើរទៅ លែងស្ដាប់សម្ដីគាត់។

ទូរសព្ទគេស្រាប់តែរោទ៍។

វាជា SMS តែក៏មិនមែនផ្ញើមកពីលេខអ្នកធ្លាប់ស្គាល់ធ្លាប់ Save ទុកដែរ។

យ៉ាងរហ័សគេក្រឡេកឃើញឃ្លាថា «មកផ្លូវលេខ៣៣០ កែង ២៤៥! ផ្ទះពណ៌ខៀវអត់ផ្លាក! មានដើមចំប៉ាធំមួយនៅកែងខាងត្បូង! ទូរស័ព្ទអញគេយកទុកអស់ហើយ!»

សម្ដីក្នុងសំណេរដូចជាចរិតឯកមានណាស់ គេប្រហែលរកបានទូរសព្ទអ្នកណា ឬគេលាក់វាបានហើយទាក់ទងមក។ តើវាទំនងដែរដែលពិធីសមោសរចម្លែកនោះដកហូតទូរសព្ទអ្នកចូលរួម?

ទោះយ៉ាងណា អារម្មណ៍គេមិនអាក្រក់ពេកទេ នៅតែអាងថាប៉ូលិសមួយឡានទៀតកំពុងតាមកន្ទុយឡានឯកមានជាប់។

«ខ្ញុំបានទទួលសាររបស់អាមាន!»

គេ Voice ទៅលោកឱិត សាម៉ុនហើយចាប់ផ្ដើមបញ្ជូនសារទៅទាំងស្រុងតែម្ដងឲ្យគាត់ពិនិត្យ។

បុរសនេះបោះជំហានវែងទៅកាន់ជំនិះអូសវាចេញ ទាំងមាត់ផ្ដាំពូហឿន៖

«ពូ! មានលេខខ្ញុំហើយមែនអត់? ពេលអ្នកនាងមកដល់ជួយស៊ីញ៉ូខ្ញុំបន្តិចផងណាពូ!»

គាត់នៅចំហមាត់ ព្រោះភាំងនឹងសកម្មភាពរហ័សរហួនតាមមិនទាន់របស់ប៉ូលិសនេះ។ គេអូសម៉ូតូជិតដល់ច្រកទ្វារតូច ទើបគាត់នឹកឃើញស្រែកសួរ៖

«ហើយអត់គិតបាយទឹកសិនទេ?»

«ឧត្ដមសេនីយ៍មានការសំខាន់ឲ្យខ្ញុំធ្វើ! ខ្ញុំឆាប់មកវិញទេទាន!»

គេឡើងជំនិះហើយបញ្ឆោចេញទៅ។

នៅតាមផ្លូវដែលឆ្ពោះទៅរកគោលដៅ ចិត្តបុរសនេះមិនបានដឹងថាអ្វីទៅដែលខ្លួនត្រូវធ្វើនោះទេ ប៉ុន្តែទ្រូងចេះតែនឹកឃើញពីករណីចម្លែកមួយចំនួនដែលបានជួបពេញមួយថ្ងៃមកនេះ។ សាជាថ្មីគេនឹកឃើញដល់សម្ដីខ្លួនឯងដែលបាននិយាយទៅកាន់មហាវីន «លោកជួល

Hacker ថៃចូលទៅកកូរបណ្ដាញផ្ទាល់ខ្លួនរបស់អាណិកជននោះ លុះដឹងថាគេក៏ខ្លាំងមិនធម្មតា លោកចាប់ផ្ដើមរត់គេច!»

សម្ដីរបស់មហាវីនប្រឹងការពារខ្លួនគេវិញ «ខ្ញុំសង្ស័យគេ បានជាចំណាយពេលតាមដានគេនិងប្រើ Hacker ម្នាក់នោះ! ព្រោះខ្ញុំទ័ល! សកម្មភាពមនុស្សម្នាក់នោះធ្វើឲ្យប៉ះពាល់ដល់អាជីវកម្មខ្ញុំហើយខ្ញុំក៏មិនដឹងដែរថាគេនិង Rose កំពុងធ្វើអ្វីនៅពីក្រោយខ្នងខ្ញុំ?»

ចិត្រាប្រាប់ខ្លួនឯងក្នុងចិត្តស្ងាត់ៗថា ប្រសិនមិនបានស្គាល់ឯកមាន មិនបានរួមការងារជាមួយគេ ក៏មិនដឹងដែរថា អ្នកនៅស្រុកខ្មែរគេលេងមធ្យោបាយលុកលុយលើទិន្នន័យកុំព្យូទ័រផុលផុសនិងធ្ងន់ៗកម្រិតនេះឡើយ។

ទូរសព្ទដែលពេញមួយថ្ងៃនេះ ខលទៅអ្នកណាក៏មិនចូល ពេលនេះរោទ៍មកហើយ…

ធម្មតាក្នុងសភាពបែបនេះគេត្រូវតែទៅឲ្យដល់គោលដៅ លើកលែងតែលេខដែលខលមក ជាលេខ ដែលគេត្រូវលើកខានមិនបាន…

គេរអ៊ូម្នាក់ឯងទាំងបើកម៉ូតូដៃមួយ…

«លោកពូ?»

ជាច្រើនខែមកហើយ ឧត្ដមសេនីយ៍សេតវិទូ ដែលអ្នកផ្សេងតែងនឹកឃើញដល់រាល់ពេលឃើញក្មួយម្នាក់នេះ គឺគ្មានអ្នកណាដឹងឡើយថា គេខ្លួនឯងមិនដែល សូម្បីតែបានឮសំឡេងគាត់។ នៅក្នុងកាលៈទេសៈនេះ ស្រាប់តែគាត់ខលមក?

នាយស័ក្ដិបួន អែបឈប់ជំនិះ ហើយចុចទទួលទាំងមាត់ស្វាគមន៍៖

«ជម្រាបសួរលោកពូ?»

«ចិត្រា! ឆាប់មកផ្ទះ ពូនៅចាំបាយ! ម៉ាក់ឯងធ្វើម្ហូបច្រើនណាស់!»

គេពិតជាអរសប្បាយ ហើយនឹកឃើញភ្លាមដល់សុភមង្គលដែលអង្គុយជុំវិញតុអាហារដែលពេញទៅដោយបរិយាកាសជុំគ្រួសារ។

ពេលនាយចំហមាត់ញញឹម សំឡេងអ្នកមីងនិស្ស័យ ដ៏ស្រស់ស្អាតលាន់មកបន្ដពីស្វាមីតាមទូរស័ព្ទល្ងើយៗ៖

«ឲ្យចិត្រាឆៀងចូលទិញទឹកឃ្មុំមកផង ផ្ទះអត់មានរលីងដុតនំម៉េចកើត?»

ភាគទី២០

«ខ្ញុំទៅមិនបានទេពូ!»

គេកាត់ចិត្តឆ្លើយតាមទូរសព្ទផូង ហើយក៏ជាវាចាដែលនិយាយស្រលះផ្ទុយពីបេះដូង។ គេចង់ជួបគាត់ណាស់ តែពេលនេះមិនអាច។

សម្ដីខ្លីមិនបាច់ពន្យល់នេះ មិនពិបាកយល់ឡើយសម្រាប់អតីតឧត្ដមសេនីយ៍ដែលប្រលូកឆ្អែតការងារជាអ្នកបង្ក្រាបបទល្មើស។ គាត់ដឹងថាក្មួយប្រុសទំនងជាស្ថិតក្នុងពេលវេលាមួយដែលអាចថា សូម្បីតែនិយាយក្បោះក្បាយបន្តទៀតក៏មិនបានផង។

គាត់នៅស្ងៀម ធ្វើឲ្យគេប្រញាប់ពន្យល់៖

«គឺ...»

«អត់អីទេ!» គាត់និយាយកាត់។

ចិត្រានៅទ្រឹងព្រោះគាត់ហាក់បីដូចជាមនុស្សដែលមានចិត្តសាស្ត្រចេះយល់ចិត្ត ហើយធ្វើការសម្រេចចិត្តរហ័ស លឿនច្បាស់លាស់ ដូចភាពល្បីរន្ទឺនៃស្នាដៃរបស់គាត់ដែលក្មួយម្នាក់នេះធ្លាប់តែឮ។

គេគិតខ្លួនឯងភ្លាមៗថា តើក្មួយម្នាក់នេះនឹងរំភើបយ៉ាងណា ប្រសិនបើពេលនេះបានអង្គុយក្នុងពេលរាត្រីជជែកជាមួយគាត់ស្ដាប់បទពិសោធន៍ ត្រងយកដំបូន្មាន?

ប៉ុន្តែឱកាសមកមិនត្រូវវេលា។

សំឡេងគាត់បន្ថែមពេលគេមិនទាន់បិទ៖

«ពូនៅកំដរម្ដាយឯង ចាំឯងមកវិញ!»

«កុំអីពូ! ខ្ញុំប្រហែលយប់ណាស់!»

គាត់នៅស្ងៀមមួយដង្ហើម ទើបតប៖

«អូខេ! បាន! អាទិត្យក្រោយពូមកជួបឯងឲ្យទាល់តែបាន!»

គាត់ប្រហែលជាដឹងថា ក្មួយនេះមិនងាយដាច់ចិត្តបិទទូរសព្ទបានជាគាត់ជាអ្នកបិទមុន...

គេនៅឈប់សំកាំងស្ងៀមសម្លឹងទូរសព្ទ មិនព្រមបន្តដំណើរទៅមុខទៀតសោះ។ ចិត្តនាយរារែកតែដៃនាយចុចទៅយ៉ាងញាប់៖

«ពូ! ក្មួយម្នាក់នេះនៅតែល្ងង់! ធ្វើប៉ូលិសយូរហើយនៅតែគ្មានកេរ្តិ៍ឈ្មោះអីនឹងគេ!»

ស្រាប់តែគាត់ឆាតបកមកវិញ...

«បើវាសំខាន់ណាស់ចាំចង់បាន!»

គាត់ឆ្លើយខ្លី ហើយមើលទៅហាក់បីដូចជាយល់ចិត្តក្មួយច្បាស់ថា នាយស័ក្តិបួនហាក់មានពាក្យសម្ដីជាច្រើនចង់ទម្លាយ មិនអាចនិយាយផ្ទាល់បែរជាដាច់ចិត្តឆាតទៅគាត់។

«វាមិនសំខាន់សម្រាប់ពូ តែក្មួយចង់បានណាស់! កេរ្តិ៍ឈ្មោះ សក្តិលើស្មា ជាបំណងនៃប៉ូលិសគ្រប់គ្នា!»

គេសរសេរតបទាំងបេះដូងលោត។

នៅចំពោះមុខ មានប្រស្នាលំបាកដែលតាមថានាយអាចទៅរកគាត់ហើយសួរយោបល់ តែនាយមិនដែលគិតថាធ្វើ ព្រោះគំនិតពីរជាឧបសគ្គរហូតមកនោះគឺ«កូនប្រុសដោះស្រាយកិច្ចការខ្លួនឯងឲ្យអស់លទ្ធភាពសិនមុនពេលពឹងពាក់អ្នកដទៃ» «បើពូចង់សម្រាកពីការងារអស់នេះ ហេតុអីត្រូវទៅរំខានគាត់!»។

ឆាតនៅតែលោតមកបន្ត៖

«សក្តិពាក់មិនសូវសំខាន់! សំខាន់ត្រង់ថា អ្នកពាក់សក្តិសមនឹងវាដែរអត់?»

ចិត្តនាយផ្ទុះធ្លាយ ព្រោះបុរសចំណាស់ហាក់បីដូចជាកំពុងថាឲ្យនាយច្រើនជាងកំពុងលើកទឹកចិត្ត។ គេចុចតបញ័រដៃ៖

«ក្មួយយល់ហើយ!»

ប្រុងថាឈប់និយាយ ស្ពាយប្រយោគ ទៅតាមទ្រូងបន្តគោលដៅ ស្រាប់តែគាត់ចុចមកទៀត៖

«ឯងមិនយល់ទេ!»

ចិត្រាជ្រួញចិញ្ចើម។ដៃគេវាយអក្សរតបទៅវិញ៖

«ហេតុអីទៅ?»

«ដោះស្រាយរឿងក្តីនីមួយៗ ការវាយតម្លៃរហ័សពេក ប្រើអារម្មណ៍ពេក អាចបាត់បង់ថាមពលអស់ពាក់កណ្តាលទៅហើយ! មនុស្សយើងអាចធ្វើគ្រប់យ៉ាងឲ្យល្អបំផុតបានតែក្នុងពេលណាដែលយើងមិនកើតទុក្ខពេក មិនសប្បាយពេកប៉ុណ្ណោះ!»

«សូម្បីពេលនេះយើងកំពុងបាក់ទឹកចិត្តនឹងសម្តីរបស់គាត់ក៏គាត់ដឹងដែរ?»

គេគិតទាំងពិចារណាចុះឡើង មុនពេលមាត់ដាក់សំណួរទៅវិញ៖

«ចុះប្រសិនបើ... ឧបមាថាពេលនេះ មិត្តភ័ក្តិពូកំពុងមានបញ្ហា គេកំពុងស្ថិតនៅក្នុងបេសកកម្មហើយ ពូរង់ចាំនៅទីនេះ  ពូក៏ទទួលខលពីគេមកថា គេនៅទីណាមួយហើយត្រូវការជំនួយ!»

ឆាតលោតមកវិញយឺតៗ បើធៀបទៅនឹងសន្ទុះចិត្តរង់ចាំចម្លើយរបស់នាយ៖

«ចំណុចសំខាន់នៅត្រង់ថា ពេលនេះឯងអាល័យតែសួរឯងយឺតពេលហើយ!»

គេដកដង្ហើមធំតបសារ៖

«មែនហើយ! អត់បានការទេខ្ញុំ!»

ស្រាប់តែគាត់តបមកវិញយ៉ាងរហ័ស៖

«បញ្ហាធំគឺនៅត្រង់ពូនិយាយភ្លាម ឯងក៏បន្ទោសខ្លួនឯងភ្លែត! ពូមិញនេះនិយាយថាឯងយឺតតាមពិតពូលចិត្តឯងទេ! ត្រូវចាំរឿងបញ្ញាសមួយ នៅរាល់ពេលដែលអ្នកណាម្នាក់មានបំណងប្រឆាំងនឹងឯង គេនឹងដឹងថាមួយជំហានបន្ទាប់ឯងឈានទៅណា? ការធ្វើតាមអារម្មណ៍ភាគច្រើនធ្វើឲ្យភ្លាត់ចូលក្នុងឧបាយកលគេ!»

គេរងីរងើហើយចុចទូរសព្ទទៅសួរតែម្តង៖

«ពូ! ខ្ញុំមិនយល់ទេ! ដូចរឿងនេះអ៊ីចឹង អាមានវាទាក់ទងមក ប្រាប់កន្លែងដែលវាកំពុងនៅ! វាកំពុងស្ថិតក្នុងបេសកកម្មដែលអាចមានគ្រោះថ្នាក់! អាមានមិនមែនជាសត្រូវខ្ញុំទេ មែនដែរអត់?»

បុរសនោះសើចវែងអន្លាយ ក្នុងពេលកំឡោះយើងកំពុងរង់ចាំស្តាប់ដោយអន្ទះសា។ បន្តិចក្រោយមកគាត់និយាយបន្ត៖

«នៅក្នុងប្រតិបត្តិការ គ្មានអ្នកណាជាមិត្ត គ្មានអ្នកណាជាញាតិជាផៅ ជាអ្វីផ្សេង ក្នុងបេះដូងប៉ូលិសដែលកំពុងជាប់បេសកកម្មនោះទេ! គ្មានអ្នកណាមួយត្រូវជាអ្វីនឹងយើងទាំងអស់! សកម្មភាពអ្នកណាក៏ដោយឲ្យតែអាចនាំបញ្ហាដល់គោលដៅធំរបស់យើង អាចត្រូវជាប់សង្ស័យហើយគិតគូរដេញដោលមុនចេញសកម្មភាព!»

ចិត្រានៅស្ងៀមបើកភ្នែកធំៗរង់ចាំស្តាប់សម្តីឪពុកមាដោយប្រុងប្រយ័ត្ន។ គេនៅតែគិតមិនយល់ ពិចារណាបែងចែកមិនបានច្បាស់លាស់សោះទេថា តើសម្តីនេះគាត់ចង់ពញ្ញាក់មិនឲ្យគេទុកចិត្តសាររបស់ឯកមានឬអ្វី?

គេសួរវិញមួយៗ៖

«ចុះបើ... ចុះបើពេលនេះក្មួយកំណត់គោលដៅធំ គឺកន្លែងដែលឯកមានប្រាប់! តើនេះជាការកំណត់ត្រឹមត្រូវដែរទេ?»

អតីតឧត្តមសេនីយ៍សើចតិចៗមុនពេលឆ្លើយ៖

«ក្មួយដឹងចម្លើយហើយនៅមកសួរពូ?»

«ក្មួយមិនច្បាស់ខ្លួនឯងទេ!»

គេនិយាយទាំងខ្វល់ខ្វាយពិចារណាចុះឡើង ឡើងចុះ មិនឈប់ឈរ។ សំឡេងបុរសនេះតែបន្តមក៖

«អ៊ីចឹង ក្មួយគិតម្តងទៀត ចាំកំណត់គោលដៅសាជាថ្មី!»

«ហេតុអី? ការគិតម្តងទៀតអាចកាន់តែយឺតពេលក៏ថាបាន! អាចថាអស់ឱកាសក៏ថាបាន!»

ប៉ូលិសវិទូនិយាយតបស្រាលៈ

«មានតែមនុស្សស្លាប់បាត់ទេ ដែលអស់ឱកាស!»

គេជ្រួញចិញ្ចើមរហូតដល់ភ្នែក។

សំឡេងគាត់លាន់មកទៀត៖

«ប៉ូលិសចេញទៅខុសគោលដៅ ឬចេញទៅរកគោលដៅដោយងងឹតងងុល មិនដឹងថាអ្វីជាផែនការ ធ្វើសកម្មភាពបែបណា ពេលខ្លះសូម្បីតែជីវិតក៏យកមកវិញមិនបានដែរ! ចំណែកប៉ូលិសដែលមានគោលដៅត្រឹមត្រូវ គេដឹងថាអ្វីទៅគ្រោះថ្នាក់ អ្វីទៅអំណោយផល!»

គេនៅស្ងៀមលែងមានអ្វីអាចតបតបាន បណ្ដោយឲ្យឪពុកមាពោលបន្ត៖

«គោលដៅរបស់ក្មួយប្រហែលពុំមែនអ្វីដែលឯកមានកំពុងប្រាប់ទេ ប្រហែលជាអ្វីដែលឯកមានកំពុងធ្វើ!»

«មានអីខុសគ្នា?»

គេសួរវិញបន្ទាន់ គាត់ក៏ឆ្លើយវិញមួយៗមិនប្រញាប់៖

«គេទៅដើម្បីអ្វី ខុសគ្នាស្រលះ គឺទៅកន្លែងណា!»

ចិត្រាបើកភ្នែកធំៗ ... ចំណែកលោកមាគិតតែពីពន្យល់មកថែម៖

«ក្នុងពេលដោះស្រាយសំណុំរឿង! គោលដៅភាគច្រើនពុំមែនជាទីកន្លែងទេ តែសំដៅលើមនុស្ស!»

ចិត្តនាយនឹកឃើញភ្លាមដល់រឿងជាច្រើនបន្តកន្ទុយគ្នា។

សម្ដីឧត្ដមសេនីយ៍ឱត សាម៉ុន លាន់មកវិញក្នុងការចងចាំ «ចាំខ្ញុំនៅផ្ទះហើយតាមមើលអមរាដាមិនឲ្យឃ្លាតពីភ្នែក!» «ទុកចិត្តចុះទាន!»។

គេនឹកឃើញបន្ទាន់ដល់ស្រីតូចនោះ។ នាងមិនទាន់ចូលផ្ទះនៅឡើយ ហើយពេលនេះគេបែរជាចេញមករឹងមិនបានគិតមិនបានផ្ដាំ ព្រោះសស្រាក់សស្រាំទៅតាមសាររបស់ឯកមាន។

«ហេតុអីពូដឹង?»

គេចោទសួរពាក្យប្អូនម៉ាត់មិនទំនងនេះទៅតាមចិត្តជ្រួលខ្វល់។

លោកមានៅស្ងៀម ហាក់ទុកពេលឲ្យគេនិយាយសាជាថ្មី។ ដូច្នេះនាយស័ក្ដិប្អូនចាប់ផ្ដើមសារភាព៖

«ខ្ញុំចេញមកខុសគោលដៅហើយពូ! ភារកិច្ចខ្ញុំយាមកូនស្រីឧត្តមសេនីយ៍ឱត សាម៉ុន! ខ្ញុំត្រូវត្រឡប់ទៅវិញសិន! បើអ្នកនាងតូចនោះមានរឿងអី ក្បាលខ្ញុំរបូតមិនខាន!»

សេតវិទូសើចតិចៗ។

ចិត្រាគ្មានពាក្យអ្វីតប មានតែនិយាយលាហើយចេញម៉ូតូបកក្រោយវឹង។

………………………………

នៅមុខគេហដ្ឋានឧត្តមសេនីយ៍ចម្ងាយប្រមាណ៥០ម៉ែត្រមើលពីលើថ្នល់ទៅ គេឃើញឡានទំនើបធំចង្រ្កាងមួយ ប្រើស្លាកប៉ូលិសសំចតនៅ ហើយកូនប៉ូលិសពីរបីនាក់ច្រប់ឆ្វែលជុំវិញ។

មួយប៉ប្រិចភ្នែក គេឃើញស្រីស្អាតអមរាដា កំពុងតែយួរកាបូបឈានទៅរករថយន្ត។

ទោះបីយ៉ាងណា នាងស្រាប់តែដំអក់នៅនិយាយអ្វីម្យ៉ាងជាមួយអ្នកម៉ាឡា ចំណែកជំទាវម្ដាយមិនឃើញនៅក្បែរៗនេះទេ។

មិនសមថាស្នងការ Roy មិននៅជាមួយការងារយាមកាម មហាវីនបែរជាមកតាមមើលគូដណ្ដឹងដល់ផ្ទះថ្មើរណេះដែរ?

សភាពរបស់ស្រីស្អាតហាក់បីកំពុងរលះរលាំងចេញទៅកាន់កន្លែងណាមួយ ធ្វើឲ្យចិត្រាកើតចិត្តឆ្ងល់។ តើនាងទៅណាម៉េចក៏យើងជាអង្គរក្សផ្ទាល់បែរជាមិនដឹង?

«អ្នកនាង?»

គេស្រែកហៅឃាត់ ពេលទ្វាររថយន្តទំនើបរបស់ប៉ូលិស ដែលគេមិនធ្លាប់បានឃើញពេលនេះមានអ្នកបើកទ្វារទទួលស្រីស្អាតស្រេចទៅហើយ។ តែប៉ុន្មានដង្ហើមទៀតនាងនឹងចូលទៅជាមិនខាន។

អមរាដា ងាកមករកនាយ។ កែវភ្នែកនាងហាក់ងឿងឆ្ងល់ពេលឃើញ គេជិះម៉ូតូអែបមកយ៉ាងលឿនដូចព្យុះសង្ឃរា។

«បងឯងទៅណា? ខ្ញុំកំពុងចង់រកអ្នកណាម្នាក់យករបស់ទៅជូនជំទាវម៉ាក់!»

បានន័យថាម្ដាយនាងមិនទាន់វិលមកវិញនៅឡើយ ប្រហែលជាលោកនៅមានភារៈត្រូវបន្ត ជាមួយអ្នកជិតខាងនោះ?

វរសេនីយ៍ត្រីឆ្លើយតបភ្លាម៖

«ខ្ញុំទៅភ្លាមទាន! អ្នកនាងឡើងផ្ទះសម្រាកវិញចុះ!»

អមរាជាជ្រួញចិញ្ចើមពេលឃើញអង្គរក្សចំណាប់ចុះពីលើម៉ូតូដើរតម្រង់មក ដោយដកសោម៉ូតូមកកាន់ជាប់នឹងប្រអប់ដៃធំមាំរបស់គេ។ គេហាក់កំពុងយល់ខុសថា ពេលនេះនាងកំពុងឡើងរថយន្តទៅរកម្ដាយ។

ចិត្រាក្រឡេកញញឹម ទៅកាន់ពួកប៉ូលិសព្រោះគិតថាជាអ្នកនៅក្នុងផ្ទះកាលពីល្ងាច ដឹងអីគ្មានអ្នកណាម្នាក់ក្នុងចំណោមពួកគេជាអ្នកដែលនាយយើងធ្លាប់ឃើញមុខពីមុនមកសោះ។

«ខ្ញុំទៅរកប៉ាតើ! ប៉ាឲ្យយក Laptop ទៅ!»

ចិត្រាថ្លោះទឹកមុខ។ ទោះមិនបាច់គិតក៏គេដឹងថា លោកឱត សាម៉ុន មិនប្រើកូនស្រីធ្វើរណេះ ហើយឲ្យយកលេបថបទៅដោយមិនបានប្រាប់នាយនោះឡើយ។

នាងហុចសោឲ្យអ្នកបម្រើហើយផ្ដាំ៖

«ចូលបន្ទប់ខ្ញុំ រកថ្នាំគ្រេចដែលខ្ញុំទិញមកពីស្រុកចិន ក្រឡពណ៌ក្រហម! មីងឲ្យទៅបងអង្គរក្សនេះ ឲ្យគាត់ឆាប់យកទៅជូនជំទាវម៉ាក់!»

អ្នកម៉ាឡាទទួលសោ។

«ចាំសិនណាចិត្រ!»

គាត់និយាយមកកាន់នាយមុនពេលបកចូលទៅក្នុងផ្ទះ តែចិត្រាប្រញាប់ស្ដីឡើង៖

«អត់ទេ ខ្ញុំត្រូវទៅជាមួយអ្នកនាង!»

ដៃចុចទូរសព្ទផង មាត់គេនិយាយផងព្រោះគេត្រូវការការបញ្ជាក់ជាប្រញាប់ពីលោកឱត សាម៉ុន។ អមរាជាក្រពាត់ដៃ ទឹកមុខឆ្ងល់លាយហួសចិត្ត៖

«ខ្ញុំឲ្យបងឯងធ្វើនេះ បងឯងទារធ្វើនោះ!»

«ខ្ញុំគិតពីសុវត្ថិភាពអ្នកនាង!»

គេឆ្លើយដោយមិនខ្លាចចិត្ត មិនគិតពីអ្នកណាថាយល់យ៉ាងម៉េចទាំងអស់។

ពីកញ្ចក់ចំហៀងឡានគេឃើញពួកប៉ូលិសក្រឡេកភ្នែកមើលគ្នាជាសម្ងាត់។ អារម្មណ៍មិនល្អមួយលេចចេញឡើងពេញទំហឹង។ ទូរសព្ទលោកឱត សាម៉ុនមិនអាចទាក់ទងបានទេ ប្រសិនលោកស្ថិតក្នុងបន្ទប់សួរចម្លើយ ភាគរយច្រើនគឺទូរសព្ទត្រូវបិទ។

គេដើរវែងៗទៅក្បែរឡានដោយទឹកមុខស្ងប់ ហើយឱនឈ្ងោកសម្លឹងតែកុង។

អ្នកនៅកន្លែងបើករថយន្តទំនើបជាយុវជនម្នាក់ ទឹកមុខគេសុភាពរាបសារ សម្លឹងតបមករកមកចិត្រាវិញ ប៉ុន្តែមិនយូរប៉ុន្មាន ភ្នែកនាយឃើញស្នាក់សាក់តូចមួយលើកញ្ចឹងករបស់គេ។

ស្នាមសាក់មិនមែនតំណាងឲ្យមនុស្សអាក្រក់ទេប៉ុន្តែ បើថាប៉ូលិសខ្មែរណាម្នាក់ ដែលត្រូវបានថ្នាក់លើអនុញ្ញាតឲ្យសាក់រូបសិចស៊ីនេះបែបលើរាងកាយ ក៏រឹតតែទេទៅទៀតហើយ។

សំឡេងនាងលាន់មកស្រួយស្រោកៈ

«បងឯងខ្លាចអី! ខ្ញុំស្គាល់ពូពិសិដ្ឋច្បាស់ គាត់អ្នកតេមកផ្ទាល់!»

រហ័សដូចផ្លេកបន្ទោរ អង្គរក្សផ្ទៀងស្ដាប់ពាក្យនាងផង ភ្នែកគេរេសម្លឹងពិនិត្យអ្នកបើកបរគ្រប់ចំណុចសំខាន់។

ស្មា ដៃ ចង្កេះ ជើង ទោះបីគេអង្គុយ ចិត្រាដឹងថាគេមានរាងកាយដ៏រឹងមាំហើយស្វាហាប់។ ទឹកមុខអ្នកបើកបរនៅតែស្លូតបូត នឹងនស្ងាត់ស្ងៀម តែភ្នែកគេឆ្លៀវឆ្លាត។

នៅក្បែរចង្កឹះលេខឡាន វរសេនីយ៍ត្រីក្រឡេកឆ្វាចទៅឃើញទូរសព្ទទំនើប២ ឬបីគ្រឿង នឹងប័ណ្ណឥណទានមួយសន្លឹក ក្បែរកាហ្វេពីរកែវ។ គេដកភ្នែកមកវិញ ហើយរេទៅរកកញ្ចក់ចំហៀងម្ដងទៀត តែម្ដងនេះលឿនជាងមុន...

ច្បាស់ការណាស់ប៉ូលិសម្នាក់នៅឆ្វេងដៃកំពុងលូកដៃទៅក្នុងចង្កេះខ្លួនឯង ហើយនៅម្ខាងទៀតក៏មានកាយវិការប្រុងប្រៀបរួចទៅហើយដែរ។

សម្ដីលោកមាដែលទើបនឹងឮលាន់ត្រឡប់មកវិញ «នៅក្នុងប្រតិបត្តិការ គ្មានអ្នកណាជាមិត្តគ្មានអ្នកណាញាតិ គ្មានអ្នកណាមួយត្រូវជាអ្វីនឹងយើងទាំងអស់! សកម្មភាពអ្នកណាក៏ដោយ

ឲ្យតែអាចនាំបញ្ហាដល់គោលដៅធំរបស់យើង គិតគូរដេញដោលឲ្យច្បាស់មុនចេញសកម្មភាព!»

គេថយយឺតៗមកក្បែរស្រីស្អាត ជាមួយសំណួរមួយៗ៖

«មិនមែនលោកឧត្តមសេនីយ៍ទូរសព្ទមកផ្ទាល់ទេ?»

នាងមិនទាន់ឆ្លើយអ្វីផង គេលើកដៃរុញស្រីស្អាតមួយទំហឹងកូនប្រុស ទៅផ្ទប់លើទ្វារភូមិគ្រឹះលាន់ត្រឡប់មកវិញ។ គ្រាប់កាំភ្លើងចាប់ផ្ដើមផ្ទុះលាន់មក ចំណែករាងកាយនាយស័ក្តិបួនដែលកំពុងរមៀលគេចប្រផាប់ចាប់ប្រភីងនោះ គឺមានគោលដៅឆ្ពោះទៅរកនារីអ្នកមានដែលនៅមិនទាន់ក្រោកឡើងមករួចផងនោះ។

គេដឹងថាការផ្ទុះកាំភ្លើង និងនាំឲ្យអ្នកខាងក្នុងផ្ទះដឹងការណ៍ហើយរត់ចេញមកជាជំនួយទាន់ពេល។ ដៃស្ដាំនាយបញ្ចេញអាវុធខ្លី ជាមួយនឹងសកម្មភាពក្រឡាស់ទៅនៅពីមុខនាង ផ្ងង់រកមើលគោលដៅ។

«ស្រីនោះត្រូវយកមកទាំងរស់!»

សំឡេងអ្នកបើកឡានម្នាក់នោះបញ្ជាចេញមក ហើយដៃគេលើកកាំភ្លើងខ្លីបញ្ចេញតាមកញ្ចក់តម្រង់មកទ្វារ ដើម្បីបញ្ឈប់មិនឲ្យអ្នកខាងក្នុងចេញមកបាន។

ប៉ូលិសប៉ុន្មាននាក់រត់រឹងមកពីខាងក្នុងតូបយាម ជាមួយកាំភ្លើងក្នុងដៃ។

សម្រាប់ទិសដៅបួនកន្លែងដែលជនល្មើសកំពុងតាំងនៅ ហើយខ្លួនឯងមានតែម្នាក់ ព្រមទាំងជាប់ភារកិច្ចរារាំងគ្រាប់ឲ្យនារីនេះផង ចិត្រាស្រែកឮៗទៅកាន់សន្តិសុខ៖

«នាំអ្នកនាងចូលផ្ទះ!»

គ្រាប់ទីមួយរបស់គេបោលរហ័សជាងថ្វីដៃអ្នកបើកបរ ធ្វើឲ្យបុរសនោះអាក់ខានការបាញ់រាំងផ្លូវសន្តិសុខ ហើយគ្រាប់ទីពីរទៀត បង្ខំឲ្យមនុស្សមានសាក់លើកញ្ចឹងកត្រូវតែបោះបង់ការប្រយុទ្ធដកដៃចូលទៅក្នុងឡាន ជាន់ហ្គែរថយ។

ទោះយ៉ាងណា ទិសដៅ២ផ្សេងគ្នាបានបាញ់បង្អាក់សន្តិសុខទាំងទ្វេ ដោយបំបុកជើងពួកគេឲ្យដួលស្រឹប បណ្តោយឲ្យធីតាកូនឧត្តមសេនីយ៍ត្រដាបត្រដួសក្រោកឡើងតែឯងទាំងទឹកមុខតក់ស្លុត។

អ្នកនៅសល់ចុងក្រោយ រត់មកប្រទាញនាំអមរាដាឆ្ពោះទៅរករថយន្តដែលអ្នកបើកបរកំពុងរ៉ឺយ៉ៃថយមកលាន់កក្រើកមេឃ។

កង់រថយន្តទាំងបួនទើបជាគោលដៅបន្ទាន់ក្នុងពេលនេះ។ ចិត្រាប្រើគ្រាប់ដែលនៅសល់បង្អាក់យានជំនិះជនល្មើស ល្មមពេលប៉ូលិសក្លែងបន្លំម្នាក់នោះអូសអមរាដាមកដល់ក្បែរគូទឡានទៅហើយ។ គ្នាវាពីរនាក់ផ្សេងទៀតបោះបង់ចោលសន្តិសុខដែលត្រូវរបួស ហើយម្នាក់ទៀតកាន់កាំភ្លើងភ្ជង់ការពារបើកផ្លូវ ឲ្យគូកនអូសនាំស្រីស្អាតបង្ខំឡើងឡាន។

ទូរសព្ទដៃហោះរឹងចេញពីហត្ថាក្ជួយប្រុសប៉ូលិសល្បី តម្រង់មករកដៃអ្នកអូសនាំអមរាដា។ ម្នាក់នោះស្រែកអូយដោយឈឺចាប់មិនអាចទ្រាំបាន ចំណែកអ្នកកាន់កាំភ្លើងបង្វែរមករកចិត្រា។

ស្នូរឡានបោលមកដល់លាន់រង្គើរាត្រីកាល ហើយសំឡេងស្រែកសន្ធាប់លាន់មកពីចម្ងាយ៖

«ដាក់កាំភ្លើងចុះ!»

ប៉ូលិសមកដល់ហើយ។ នេះទើបប៉ូលិសមែនទែនព្រោះចិត្រាឃើញស្រមោលស្នងការ Roy ទោះបីបុរសនោះនៅឆ្ងាយពីទីកើតហេតុបន្តិចក្តី។

មនុស្សជាច្រើនរត់ចេញមកពីក្នុងផ្ទះ ដូច្នេះចិត្រាដឹងថាមធ្យោបាយរបស់ជនពាលគ្មានអ្វីក្រៅពីការពារខ្លួនដោយប្រើចំណាប់ខ្មាំងសំខាន់ក្នុងដៃនោះទេ។

ប៉ូលិសទាំងបីទាញយករាងកាយអមរាដារហ័សជាង មុនក្រោមកាណុងកាំភ្លើងជាច្រើនភ្ជង់មក ពីគ្រប់ទិស។ ដូច្នេះប្រសិនបើនាងត្រូវបានរុញបញ្ចូលឡាន អ្វីៗនឹងរលាយ។

«ពួកឯងទម្លាក់កាំភ្លើង!»

ភ្នែកនាយ Roy ក្រឡេត ទឹកមុខប្រែទៅជាខ្មៅរោល ផ្តោតមកសម្លឹងនារីគូដណ្តឹងដែលកំពុងឈឺចាប់ក្នុងដៃមនុស្សអាក្រក់។

ពួកដៃដល់ ទំនងជាកំពុងរឹតដង្ហើមនាងខ្លាំងៗ ព្រោះវាកំពុងស្ថិតក្នុងសភាពភ័យតក្កមា។

ប្រសិន Roy ជាប៉ូលិសពេញដោយបទពិសោធន៍ គេគួរតែដឹងដោយខ្លួនឯងហើយថា ដំណាក់កាលនេះគ្មានកាំភ្លើងណាមួយក្នុងចំណោមកងកម្លាំងដ៏ច្រើនរបស់គេ អាចមានលទ្ធភាពសង្ឃឹមដណ្ដើមយកកូនស្រីឧត្ដមសេនីយ៍ឲ្យរបូតពីដៃជនល្មើសបានទេ ព្រោះក្បាលនាងកំពុងត្រូវភ្ជង់ជាប់ម៉ឺងទៅហើយ។

រថយន្តបើកទ្វារខាងក្រោយស្វាគមន៍ឲ្យវាឲ្យអូសនារីនេះចូលទៅ ចំណែកអង្គរក្សស័ក្តិបួនសម្លឹងរកឱកាសផ្លាស់ប្ដូរអ្នកបើកបរចេញ។

ពេលដែលអ្នកបើកបរភ្ជង់សំដៅបាំងខាងក្រោយហើយជើងគេត្រៀមតែជាន់ហ្គែរចេញ គេមិននឹកស្មានទេថា កញ្ចក់ចំហៀងខ្លួនត្រូវគោះប៉ូកៗដោយរបស់រឹង។

បុរសមានសាក់ ងាកមកសម្លឹងចិត្រាដែលប្រើចុងស្រួចនៃសោម៉ូតូរបស់គេវាយប៉ូកៗពេញកម្លាំងកូនប្រុសហើយវាយមិនឈប់រហូតដល់កញ្ចក់ចាប់ផ្ដើមបែកប្រេះ។

រវាងថយឡានគេចចេញ និងរង់ចាំទម្រាំស្រីស្អាតត្រូវបានរុញចូលមកដល់សិនជាជម្រើសដ៏ពិបាកសម្រេចចិត្តរបស់នាយតែកុងម្នាក់នេះ។

គេខាំមាត់សម្លក់ផង ខឹងដាក់ចិត្រាព្រោះបានចិត្តថា កញ្ចក់នោះប្រេះស្រាំខ្លាំងឡើងៗ តែវាមិនព្រមបែកសោះ។

ចិត្រាឈប់ចលនា... ធ្វើឲ្យអ្នកបើកបរតាមមើលគេមិនដាក់ភ្នែក...

ចិត្រាថយចេញឆ្ងាយពីយាន អ្នកបើកបរចាប់ផ្ដើមញញឹមចំអកនាយ...

នាយស័ក្តិបួនខាំមាត់ គេដឹងថាការបំបែកកញ្ចក់តូចប្រាកដជាតឹងជាងកញ្ចក់ធំ ដូច្នេះហើយគេដូរទិសដៅទៅខាងមុខឡាន ។

ក្រោមភាពតក់ស្លុតបើកភ្នែកស្រលាំងកាំងប៉ុនៗពងមាន់របស់អ្នកនៅខាងក្នុងឡាន ដែលពេលនេះសើចលែងសម អង្គរក្សដោះអាវមករុំកែងដៃ ហើយអុកបំបែកផុងៗដូចមិនដឹងឈឺ ដូចដែកមិនដឹងក្ដៅ។

កញ្ចក់ខាងមុខខ្ទាយប្រាវ... អ្នកបើកបរលើកដៃទាំងទ្វេ បាំងអំបែងដែលខ្ទាតសន្ធប់ចូលមកខាងក្នុង។

ដៃអង្គរក្សលូកមកទាញកអាវគេ ជាប់ធ្វើឲ្យគេលែងគិតអ្វីក្រៅពីជាន់ហ្វ្រាំបំបោលឡានទៅមុខ។ អមរាជាត្រូវភ្លាត់ចេញពីទ្វារឡាន ហើយដួលច្រងាងរបូតពីដៃពួកអ្នកក្លែងជាប៉ូលិស...

ភាគទី២១

កង់រថយន្តត្រូវបង្ខំឲ្យឈប់ង៉ឹត..... ចម្ងាយប្រមាណជា៥០ម៉ែត្រពីទីកើតហេតុ។

ចិត្តអ្នកបើកបរដែលចង់រ៉ឺយែរថយក្រោយពេញទំហឹង មិនអាចទៅរួចទៀតឡើយ ព្រោះអ្នកដែលចាប់កអាវគេមិនត្រឹមតែមិនព្រមលែងដៃទេ គឺទាញគេមកផ្ទឹបនឹងចង្កូតឡានកម្រើកលែងរួចតែម្តង។

បុរសមានសាក់ ស្រែកទាំងក្តៅក្រហាយ៖

«អ្អែងរៀនក្បាច់តុកកែមកពីណាអាប្រកាច់?»

ចិត្រាខាំមាត់ ព្រោះគេបានលែងកម្លាំងទម្ងន់ខ្លួនទាំងស្រុងទៅលើកំភួនដៃទាំងពីរ ដែលទាញកអាវជនល្មើស។ ស្នូរជំហានក្រុមប៉ូលិសរត់ស្រមកដល់បន្តបន្ទាប់គ្នា...

សំឡេងប៉ូលិសដែលខ្លួនមិនធ្លាប់ស្គាល់និយាយមកពីក្រោយខ្នង៖

«ចាប់បានទាំងអស់ហើយ!»

ចំណែកឯនៅទ្វារខាងអ្នកបើកបរ ប៉ូលិសពីរនាក់ផ្សេងទៀតកំពុងបើកកន្ត្រាក់ហើយមកអូសនាំជនល្មើសចុះ។

ចិត្រាលែងដៃ បន្ធូរដង្ហើម...

វគ្គ អ្នកបាត់ខ្លួនទី៥

ជំទាវជាអ្នកម្តាយរបស់អមរាជាអង្គុយជូតមុខមាត់ឲ្យកូនស្រីបណ្តើរ ដកដង្ហើមខ្វល់ខ្វាយចិត្តបណ្តើរផង។

«លោកប្រុសមកដល់ឬនៅម៉ាឡា? បើកូនប្រពន្ធមានរឿងដល់ថ្នាក់នេះ លោកប្រុសឯងនៅរវល់ការងារជាតិទៀត ឲ្យដឹងគ្នាច្បាស់ម៉ងទៅ!»

គាត់ស្រដីទាំងទោមនស្ស ព្រោះប្រសិនបើស្ថានការណ៍មុននេះមិនត្រូវបានដោះស្រាយទាន់ តើឲ្យគាត់ស្វែងរកកូនស្រីសំណព្វតែមួយបានមកវិញដោយវិធីណា?

សំឡេងលាន់មកពីទូរទស្សន៍ដាស់អារម្មណ៍ស្រ្តីស្រ្តីអភិជន ឲ្យងាកទៅតាមដាន៖

«ជនល្មើសមួយក្រុមមានគ្នាប្រមាណ៤នាក់សង្ស័យថា ជាក្រុមដែលមានទាក់ទងនឹងបទល្មើសបាត់ខ្លួនមុនៗ ពេលនេះត្រូវបានឃាត់ខ្លួនបន្ទាប់ពីពីប៉ុនប៉ងចាប់ពង្រត់កូនស្រីមេប៉ូលិសព្រហ្មទណ្ឌនៅនឹងមុខគេហដ្ឋានអ្នករងគ្រោះតែម្តង! តោះមកស្តាប់ លោកស្នងការ Roy ផ្តល់ព័ត៌មានជុំវិញហេតុការណ៍ ដែលទើបនឹងបានកើតឡើងមុននេះមិនដល់មួយម៉ោង! គឺព័ត៌មានក្តៅៗតែម្តងបាទ!»

អមរាងាងើបមុខ តាមដានអាការម្តាយដែលកំពុងខឹងអន់ចិត្ត ពេលនេះបែរមកជាសោមនស្សរីករាយជាខ្លាំងពេលឃើញវត្តមានអនាគតកូនប្រសាកំពុងផ្តល់បទសម្ភាសន៍។

សំឡេងបុរសសក្តិធំលាន់មកបន្តពីអ្នករាយការណ៍ព័ត៌មាន៖

«វាពុំមែនជារឿងចៃដន្យដែលប៉ូលិសក្រុងយើងអាចក្របួចបានក្រុមនេះទេ! ពួកគេជាមុខសញ្ញាដែលយើងបានតាមដានជាច្រើនពេលមកហើយ! ដំណាក់កាលនេះ ប៉ូលិសមិនអាចធ្វើការសន្និដ្ឋានអ្វីទាំងអស់ ប៉ុន្តែយើងសង្ឃឹមថា ការចាប់ខ្លួនដ៏ធំនេះ នឹងនាំមកជាថ្មីនូវទំនុកចិត្តរបស់សាធារណជន!»

នាងឃើញបទសម្ភាសន៍នឹងការអួតអាងរបស់បុរសនេះហើយ ក៏ងាកមុខចេញទាំងជ្រួញចិញ្ចើម។ មិនមែនមានតែនាងម្នាក់ទេដែលឃើញជាក់ស្តែងថា កុំតែអង្គរក្សស័ក្តិបួន ប្តូរជីវិតឃាត់ផ្លូវអ្នកបើកបរនោះ មិនដឹងថាវាសនាខ្លួនពេលនេះក្លាយទៅជាអ្វីខ្លះផង។

នារីតូចដឹងទៀតថា ប៉ូលិសផ្សេងៗមិនហ៊ានបកអាក្រាតអ្វីអំពីរបៀបយកគុណូបការៈរបស់មេកោយខ្លួនក៏ពិតមែន ប៉ុន្តែអ្នកដែលជាមេអួតជាងគេនោះគួរតែចេះខ្មាសដោយខ្លួនឯង។

នៅចំហៀងខ្លួន អ្នកម្តាយនៅតែជញ្ជក់មាត់អួតសរសើរមិនដាច់៖

«ហឿន! ម៉ាឡា ឃើញអត់ ក្មួយ Roy មានសមត្ថភាពជាងពួកប៉ូលិសចាស់ៗ! ហើយអមរាជា កូនគួរតែឆាប់រៀបការហើយ! មានអ្នកការពារ ម៉ាក់ធូរចិត្តជាងហ្នឹង!»

អមរាជាតបតវិញទាំងទោមនស្សះ

«មនុស្សអ្នួត! បើគ្រាន់បើណាស់ រកស្រីៗបាត់ខ្លួនទាំងបួននាក់ហ្នឹងឲ្យឃើញសិនមក!»

លោកជំទាវងាកមកសម្លឹងមុខកូនស្រីវិញមួយរំពេចព្រមទាំងបន្ទោសស្រាលៗ៖

«និយាយអីអាក្រក់ស្តាប់ដាក់គូដណ្តឹងម្ល៉េះកូន?»

ស្រីស្អាតធ្វើមុខក្រញូវមិនតប ធ្វើឲ្យអ្នកម្តាយទ្រាំមិនបានក៏បន្ថែមមកទៀត៖

«ស្រុកមិនមានសុវត្ថិភាព ម៉ាក់គិតរៀបការកូនឲ្យបានឆាប់កាន់តែល្អ!»

នាងឈ្ងោកធ្វើក្រញូវមុនពេលគ្រវីក្បាលតតាត់។ នាងនៅមានភាពក្មេងសេចក្តី នៅចំពោះភ្នែកគាត់ជារឿងដែលធ្វើឲ្យកំហឹងចិត្ត និងសេចក្តីព្រួយបារម្ភរបស់ម្តាយម្នាក់កើតឡើងលាយឡំគ្នា។ គាត់បន្ថយសំឡេងហើយខ្សឹបខ្សៀវបន្ទោសះ

«មិញនេះ ក្រែងគេទើបតែជួយជីវិតយើងហើយទេហ្អីអមរាជា?»

អមរាជាមិនចង់តបតអ្វីទាំងអស់ តែចិត្តនាងតែងតែនៅមិនសុខពេលនឹកឃើញដល់បុរសស្នងការ និងការនិយាយបូរបាច់ចំពោះមុខអ្នកកាសែត ដណ្តើមគុណូបការៈតែម្នាក់ឯង។ អ្វីដែលស្រីស្អាតចាំបានគឺ នៅក្នុងស្ថានការណ៍គ្រោះថ្នាក់ មានតែអង្គរក្សម្នាក់នោះប៉ុណ្ណោះដែលមកជួយនាងទាន់ពេលពេលវេលា ហើយគេធ្វើគ្រប់សកម្មភាពដើម្បីការពារនាង មិនគិតសូម្បីតែអាយុជីវិតខ្លួនឯង។

គេនោះក៏មិនប្រាកដថាគ្មានរបួសដែរ។ នាងវេភ្នែករំពៃរកនាយ ព្រោះគិតថាគេទៅសំងំនៅឯណាក៏មិនដឹង ចំណែកជនឆ្លៀតយកមុខមាត់នោះ សូម្បីតែរំលឹកដល់ឈ្មោះនាយបន្តិចក៏គ្មានផង។

«ធ្វើជាស្នងការទាល់តែខ្លាំង ទាល់តែរឹងមាំដូចកូនប្រសាខ្ញុំនេះ!»

ស្រ្តីវាចាទាំងញញឹម ធ្វើឲ្យស្រីស្អាតជាកូនតវ៉ាភ្លែត៖

«រៀបការជាមួយអាប៊ុអួតហ្នឹងសុខចិត្តស្លាប់!»

ម្ដាយប្ដូរទឹកមុខងាកមកសម្លឹងកូនទាំងបើកភ្នែកធំៗ ចំណែកទឹកមុខបដិសេធរបស់អមរាដា មើលទំនងទៅគឺជាការពិត។ លោកជំទាវដកដង្ហើមវែងៗ រួចលើកដៃបោយបណ្ដេញពួកអ្នកបម្រើឲ្យចាកចេញ។

ស្រីតូចប្រុងក្រោកទៅរកមើលនាយអង្គរក្សដែលជាអ្នកជួយជីវិតខ្លួនពិតប្រាកដ ស្រាប់តែម្ដាយទាញដៃឲ្យអង្គុយចុះទាំងថាស្ដី៖

«បើខាងប្រុសឮគេអន់ចិត្តរបៀបណាទៅ! សម្ដីនិយាយចេញមកគ្មានពីរោះពិសាចំពោះគេ ឲ្យសមជាមនុស្សមានពូជត្រកូលអីសោះ! ម៉ាក់មិនគាំទ្រទេណាអមរាដា!»

«តែប៉ាគាំទ្រកូន!»

សំឡេងឧត្ដមសេនីយ៍ ឱត សាម៉ុន លាន់មកពីមាត់ទ្វារធ្វើឲ្យលោកជំទាវកាន់តែនឹកសៅហ្មងចិត្ត ចំណែកអ្នកនាងតូចញញឹមពព្រាយរត់ទៅទទួលឪពុក។

ឧត្ដមសេនីយ៍ដោះមួក ហុចមកឲ្យកូនស្រី ហើយសម្លឹងពិនិត្យនាងពីក្បាលដល់ចុងជើង។

«ត្រូវត្រង់ណាខ្លះ?»

នាងគ្រវីក្បាលទាំងញញឹម។

ពីរនាក់ឪពុកនិងកូននេះហាក់បីដូចត្រូវគ្នាប្ដូរផ្ដាច់ពីពេលណាមកមិនដឹង ជំរុញឲ្យចិត្តលោកជំទាវដែលអន្ទះសារង់ចាំដំណឹងប្ដីពេញមួយល្ងាចមកហើយ ហាក់នឹកច្រណែនកើតក្ដីចង់ពោលពាក្យផ្ទាញ់ផ្ទាល។

គាត់បន្លឺសំឡេងលាយប្រយោគស៊កសៀត៖

«មានអ្នកខ្លះដាច់ចិត្តមកអើតផ្ទះហើយហ្អី?»

ទោះមាត់ថាដូច្នេះក្ដី ក៏គាត់នៅតែមកទទួលអាវក្រៅពីស្វាមីនិងកាបូបធ្វើការ ទាំងមាត់ឆ្លៀតនិយាយឌឺដងមិនឈប់៖

«បើកូនមានរឿងអ្វី ហើយប៉ាៗថ្មើរណោះទើបនឹងបង្ហាញព្រះភក្ត្រ តើឲ្យខ្ញុំសង្ឃឹមអ្នកណា! នេះកុំតែអនាគតកូនប្រសាខ្ញុំ...»

«គឺអង្គរក្សស័ក្តិប្អូនរបស់ប៉ា! គេជាមនុស្សឆ្លាត គេដឹងការណ៍ទាន់ពេល ហើយក្លាហាន...!»

កូនស្រីវាចាកាត់ដូច្នេះធ្វើឲ្យលោកជំទាវចងចិញ្ចើម ចំណែកលោកឱត សាម៉ុន ញញឹមចាំស្តាប់បន្ត។

អមរាជានិយាយអ្វីដែលនាងពិតជាចង់និយាយចេញមករ៉ាវៗ៖

«គេនោះវិញទេ ទំនងជាត្រូវរបួសណាប៉ា!»